ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

# គោលនយោបាយជាតិស្តីពី

# ធនធានរ៉ែឆ្នាំ២០១៨-២០២៨

រៀបចំដោយក្រសួងរ៉ែនិងថាមពល

ខែឧសភា ឆ្នាំ២០១៨

# អារម្ភកថា

ធនធានរ៉ែដែលជាធនធានធម្មជាតិមិនកកើតឡើងវិញតម្រូវឱ្យមានការគ្រប់គ្រងប្រកបដោយការប្រុងប្រយ័ត្នខ្ពស់បំផុត។ តម្រូវការនៃការអភិវឌ្ឍត្រូវមានតុល្យភាពជាមួយនឹងតម្រូវការនៃការអភិរក្ស ដើម្បីរក្សាលំនឹងបរិស្ថាននិងចីរភាពសេដ្ឋកិច្ចសង្គម។ ក្នុងន័យនេះ **គោលនយោបាយជាតិស្ដីពីធនធានរ៉ែ ឆ្នាំ២០១៨-២០២៨** ត្រូវបានដាក់ចេញដោយផ្អែកលើការគិតគូរយ៉ាងហ្មត់ចត់អំពីបច្ចុប្បន្នភាពសេដ្ឋកិច្ច នយោបាយ និងសង្គមកម្ពុជា និងអនាគតនៃប្រជាពលរដ្ឋកម្ពុជាជំនាន់ក្រោយ។

ពិតណាស់ហើយ ធនធានរ៉ែមួយចំនួនមិនចាំបាច់ត្រូវអភិវឌ្ឍក្នុងស្ថានភាពប្រថុយប្រថានឡើយ ប៉ុន្តែធនធានរ៉ែទាំងអស់ក៏មិនត្រូវកប់ចោល ដោយមិនគិតពីតម្រូវការជាលក្ខណៈយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍជាតិនោះទេ ហើយយើងមិនត្រូវលះបង់ឱកាសសេដ្ឋកិច្ច ដោយទម្លាក់ការទទួលខុសត្រូវក្នុងការអភិវឌ្ឍទៅលើមនុស្សជំនាន់ក្រោយទាំងស្រុងនោះដែរ។ ដូច្នេះការធ្វើសារពើភណ្ឌធនធានរ៉ែជាតិជាមូលដ្ឋានគ្រឹះដ៏សំខាន់សម្រាប់ការសម្រេចអភិវឌ្ឍឬអភិរក្សដោយសត្យានុម័តនិងគតិបណ្ឌិត។

ជាមួយគ្នានេះដែរ **គោលនយោបាយជាតិស្ដីពីធនធានរ៉ែ ឆ្នាំ២០១៨-២០២៨** នឹងដោះស្រាយនូវបញ្ហាប្រឈមមួយចំនួនដូចជាកង្វះប្រសិទ្ធភាពក្នុងការគ្រប់គ្រងធនធានរ៉ែនិងការប្រមូលចំណូលរដ្ឋការអភិវឌ្ឍដែលប៉ះពាល់ដល់បរិស្ថាន និងប្រជាសហគមន៍មូលដ្ឋានជាដើម។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាទាំងនេះ យន្តការពង្រឹងតួនាទីស្ថាប័នរដ្ឋត្រូវបានដាក់ចេញដោយផ្ដល់ការទទួលខុសត្រូវជាក់ស្ដែងចំពោះស្ថាប័នអនុវត្តពីថ្នាក់ក្រោមជាតិរហូតដល់ថ្នាក់ជាតិ។ យន្តការតម្លាភាពនិងយន្តការពិគ្រោះយោបល់ទូលំទូលាយជាមួយប្រជាសហគមន៍ អង្គការសង្គមស៊ីវិល និងវិនិយោគិនវិស័យរ៉ែរួមជាមួយនឹងការវាយតម្លៃនូវផលប៉ះពាល់បរិស្ថាន សង្គម និងសេដ្ឋកិច្ចនៅតែជាកត្តាកំណត់សម្រាប់ការធ្វើសេចក្ដីសម្រេចចិត្តក្នុងការអភិវឌ្ឍធនធានរ៉ែ។ យន្តការពង្រឹងតួនាទីស្ថាប័នរដ្ឋនឹងនាំមកនូវប្រសិទ្ធភាពក្នុងការប្រមូលចំណូលចូលរដ្ឋពីធនធានរ៉ែជាក្រឹត្យក្រម។ ដោយឡែក គោលនយោបាយជាតិនេះនឹងមិនផ្ដោតទៅលើការបង្កើនស្វ័យសារលើធនធានរ៉ែសំណង់ឡើយ ថែមទាំងផ្ដល់ការអនុគ្រោះបំផុតដើម្បីជំរុញវិស័យសំណង់ ហេដ្ឋារចនាសម្ព័ន្ធឱ្យកាន់តែមានសន្ទុះខ្លាំង និងផ្ដល់នូវតម្លៃបន្ថែមសម្រាប់ជាតិនិងប្រជាពលរដ្ឋ។

ក្នុងនាមរាជរដ្ឋាភិបាល ខ្ញុំសូមថ្លែងនូវការកោតសរសើរនិងវាយតម្លៃខ្ពស់ ចំពោះការខិតខំប្រឹងប្រែងយ៉ាងមោះមុតរបស់ក្រសួងរ៉ែនិងថាមពល ក្នុងការរៀបចំតាក់តែង **គោលនយោបាយជាតិស្ដីពីធនធានរ៉ែ ឆ្នាំ២០១៨-២០២៨** នេះ ឱ្យចេញជារូបរាងឡើងនិងមានលក្ខណៈគ្រប់ជ្រុងជ្រោយ។

ខ្ញុំមានសេចក្ដីសង្ឃឹមយ៉ាងមុតមាំថា គោលនយោបាយជាតិស្ដីពីធនធានរ៉ែនឹងជួយឱ្យសម្រេចបាននូវចក្ខុវិស័យមួយគឺអភិវឌ្ឍធនធានរ៉ែដើម្បីផលប្រយោជន៍សេដ្ឋកិច្ចនិងសង្គមប្រកបដោយអភិបាលកិច្ចល្អ និងការទទួលខុសត្រូវខ្ពស់ផ្នែកបរិស្ថាន។

ថ្ងៃអង្គារ ១៥កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែឧសភា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# បុព្វកថា

សុខសន្តិភាពដែលប្រទេសកម្ពុជាទទួលបានពេញលេញនាឆ្នាំ១៩៩៨ ក្រោមនយោបាយឈ្នះឈ្នះ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានធ្វើឱ្យខឿនសេដ្ឋកិច្ចនិងសង្គមរបស់ប្រទេសកម្ពុជាមានការរីកចម្រើនគ្រប់វិស័យ ក្នុងនោះ វិស័យរ៉ែបានចាប់ផ្តើមមានសកម្មភាពអភិវឌ្ឍន៍គួរជាទីមោទនៈ។ រ៉ែសំណង់ក៏បានដើរតួនាទីយ៉ាងសំខាន់ ក្នុងការផ្គត់ផ្គង់វត្ថុធាតុដើម មានថ្មសំណង់ ក្រួស ខ្សាច់ ឡាតេរីត សម្រាប់បម្រើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ស្ពាន វារីអគ្គិសនី ទំនប់ធារាសាស្ត្រ និងសំណង់នានាទូទាំងប្រទេស។ ផលិតផលស៊ីម៉ងត៍ដែលកម្ពុជាធ្លាប់តែធ្វើការនាំចូលទាំងស្រុងកាលពីអំឡុងទសវត្សរ៍ឆ្នាំ២០០០ ឥឡូវនេះត្រូវបានជំនួសវិញ ដោយផលិតផលស៊ីម៉ងត៍ក្នុងស្រុកដែលឆ្លើយតបបានតាមតម្រូវការសាងសង់នានា និងឈានទៅរកការនាំចេញទៅក្រៅប្រទេសក្នុងពេលអនាគតថែមទៀតផង។ ចំណែកឯ ឧស្សាហកម្មអាជីវកម្មរ៉ែមាសកម្រិតអន្តរ-ជាតិនឹងលេចចេញជារូបរាងនៅក្នុងពេលឆាប់ៗខាងមុខនេះផងដែរ។

**គោលនយោបាយជាតិស្តីពីធនធានរ៉ែ ឆ្នាំ២០១៨-២០២៨** ត្រូវបានរៀបចំឡើងដោយផ្អែកលើតថភាពនៃស្ថានភាពវិស័យរ៉ែរបស់កម្ពុជានាពេលបច្ចុប្បន្ននិងការពិនិត្យមើលដោយយកចិត្តទុកដាក់លើមេរៀន និងបទពិសោធន៍នៃការអភិវឌ្ឍធនធានរ៉ែតាមបណ្តាប្រទេសនានា ទាំងបណ្តាប្រទេសដែលមានឧស្សាហកម្មរ៉ែជឿនលឿននិងទាំងបណ្តាប្រទេសដែលកំពុងធ្វើការអភិវឌ្ឍវិស័យរ៉ែនៅក្នុងពិភពលោកនិងក្នុងតំបន់។ ឧត្តមានុវត្តជាអន្តរជាតិដែលមានភាពសមស្របនឹងស្ថានភាពវិស័យរ៉ែនៅកម្ពុជាត្រូវបានពូតផ្គុំបញ្ចូលទៅក្នុងខ្លឹមសារនៃ **គោលនយោបាយជាតិស្តីពីធនធានរ៉ែ ឆ្នាំ២០១៨-២០២៨** នេះ ដែលនៅក្នុងនោះផ្តោតសំខាន់ទៅលើការអភិវឌ្ឍធនធានរ៉ែប្រកបដោយចីរភាពនិងការទទួលខុសត្រូវខ្ពស់ដោយយកចិត្តទុកដាក់ជាចម្បងលើកត្តាធំៗចំនួនបីគឺ បរិស្ថាន សង្គម និងសេដ្ឋកិច្ច។ បញ្ហាអភិវឌ្ឍន៍សហគមន៍មូលដ្ឋានដែលមានអាជីវកម្មរ៉ែ បញ្ហាតំបន់អាជីវកម្មរ៉ែដែលមានជនជាតិដើមរស់នៅ និងបញ្ហាស្ត្រីក្នុងអាជីវកម្មរ៉ែក៏ត្រូវបានដាក់បញ្ចូលក្នុងគោលនយោបាយជាតិនេះផងដែរ។

ជាចុងក្រោយ ខ្ញុំបាទសូមថ្លែងអំណរគុណដ៏ខ្ពង់ខ្ពស់ចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានអនុញ្ញាតឱ្យក្រសួងរ៉ែនិងថាមពលបានដឹកនាំនិងរៀបចំឯកសារ **គោលនយោបាយជាតិស្តីពីធនធានរ៉ែ ឆ្នាំ២០១៨-២០២៨** នេះ និងសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅផងដែរចំពោះក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងវិនិយោគិនវិស័យរ៉ែដែលបានរួមចំណែកផ្តល់ជាធាតុចូលនានាក្នុងការតាក់តែងគោលនយោបាយជាតិនេះឱ្យមានភាពគ្រប់ជ្រុងជ្រោយនិងប្រកបដោយគុណភាព។

ថ្ងៃ សុក្រ ៩កើត ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ២០១៨

**រដ្ឋមន្ត្រី**

**ស៊ុយ សែម**

**១- សេចក្តីផ្តើម** ........ ១

**២- ចក្ខុវិស័យ** ........ ៣

**៣- គោលបំណងនិងគោលដៅ** ........ ៣

**៤- យុទ្ធសាស្ត្រនិងផែនការសកម្មភាព** ........ ៣

**គោលដៅទី១- ពង្រឹងតួនាទីស្ថាប័នរដ្ឋក្នុងការគ្រប់គ្រងនិងការអភិវឌ្ឍធនធានរ៉ែ** ........ ៣

*១- ការរៀបចំច្បាប់និងបទប្បញ្ញត្តិនានា* ........ ៣

*២- ការពង្រឹងសមត្ថភាពមន្ត្រីនិងការកសាងធនធានមនុស្ស* ........ ៤

*៣- ការធ្វើសារពើភណ្ឌធនធានរ៉ែ* ........ ៥

*៤- អភិបាលកិច្ចល្អនិងការគ្រប់គ្រងប្រកបដោយគណនេយ្យភាពនិងតម្លាភាព* ........ ៦

*៥- ការជំរុញវិនិយោគ* ........ ៧

**គោលដៅទី២- ជំរុញការធ្វើប្រតិបត្តិការធនធានរ៉ែប្រកបដោយចីរភាពនិងការទទួលខុសត្រូវ** ...៨

*១- ការអនុវត្តអភិក្រមអភិវឌ្ឍប្រកបដោយចីរភាព* ........ ៨

*២- ការគ្រប់គ្រងបរិស្ថាន* ........ ៩

*៣- ការធានានូវសុវត្ថិភាពអណ្តូងរ៉ែ* ........ ១០

*៤- ការទាញយកធនធានរ៉ែឱ្យអស់លទ្ធភាព* ........ ១១

*៥- ការអភិវឌ្ឍធនធានរ៉ែនិងតំបន់ការពារធម្មជាតិ* ........ ១២

**គោលដៅទី៣- អភិវឌ្ឍធនធានរ៉ែនិងសហគមន៍** ........ ១៣

*១- ការអភិវឌ្ឍសហគមន៍* ........ ១៣

*២- ការប្រើពលកម្មក្នុងតំបន់និងការងារយេនឌ័រ* ........ ១៥

*៣- ជនជាតិដើមភាគតិចនិងអាជីវកម្មធនធានរ៉ែ* ........ ១៥

**គោលដៅទី៤- អភិវឌ្ឍសិប្បកម្មរ៉ែនិងអាជីវកម្មរ៉ែខ្នាតតូច** ........ ១៦

*១- សិប្បកម្មរ៉ែនិងអាជីវកម្មរ៉ែខ្នាតតូច* ........ ១៦

*២- វិធានការនិងដំណោះស្រាយចំពោះអាជីវកម្មធនធានរ៉ែដែលគ្មានការអនុញ្ញាត* ........ ១៧

**គោលដៅទី៥- ធនធានរ៉ែនិងការនាំចេញ**........................................ ១៩

*១- នយោបាយនាំចេញ*........................................ ១៩

*២- ការនាំចេញផលិតផលរ៉ែក្នុងលទ្ធភាពផ្តល់នូវតម្លៃបន្ថែមខ្ពស់*........................................ ២០

*៣- ការសម្រួលពាណិជ្ជកម្ម*........................................ ២០

**៥- ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃ**........................................ ២០

**៦- សេចក្តីសន្និដ្ឋាន**........................................ ២១

**សន្ធានុក្រម**........................................ ២២

## ១- សេចក្តីផ្តើម

គោលនយោបាយជាតិស្តីពីធនធានរ៉ែរៀបចំឡើង ដើម្បីចង្អុលបង្ហាញនូវចក្ខុវិស័យ គោលបំណង គោលដៅ និងតួនាទីរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍធនធានរ៉ែដ៏មានតម្លៃរបស់ជាតិ និងដាក់ចេញនូវយុទ្ធសាស្ត្រនិងផែនការសកម្មភាពសំខាន់ៗដើម្បីធានាឱ្យការអភិវឌ្ឍធនធានរ៉ែត្រូវបានធ្វើឡើងប្រកបដោយចីរភាព ប្រសិទ្ធភាព ប្រសិទ្ធផល និងតម្លាភាពស្របតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា ដែលបានកំណត់ថា **«អភិវឌ្ឍធនធានរ៉ែ ប្រេងកាត និងឧស្ម័នដើម្បីប្រែក្លាយធនធាននេះឱ្យទៅជាប្រភពថ្មីមួយទៀតនៃកំណើនសេដ្ឋកិច្ចរបស់កម្ពុជា»**។ គោលនយោបាយជាតិស្តីពីធនធានរ៉ែនេះគ្របដណ្តប់តែលើធនធានរ៉ែដែលមិនមែនជាប្រេងនិងឧស្ម័ន។

ធនធានរ៉ែគឺជាសម្បត្តិធម្មជាតិមួយក្នុងចំណោមសម្បត្តិធម្មជាតិដ៏មានតម្លៃជាច្រើនទៀតដូចជាសមុទ្រ ព្រៃឈើ រុក្ខជាតិ និងសត្វ (Flora and Fauna) ជាដើម ប៉ុន្តែលក្ខណៈពិសេសរបស់ធនធានរ៉ែគឺជាសម្បត្តិធម្មជាតិមួយដែលមិនកកើតឡើងវិញឡើយ។ ប្រទេសដែលសម្បូរធនធានរ៉ែគឺជាប្រទេសដែលមានកំណប់មហាសាលដែលធម្មជាតិបានផ្តល់ឱ្យប្រជាជាតិនោះ។ ដូច្នេះការធ្វើអាជីវកម្មទាញយកផលពីសម្បត្តិធម្មជាតិទាំងនេះត្រូវតែធានាឱ្យបាននូវចីរភាព ផ្តល់នូវភាពសុខដុម និងភាពរីកចម្រើនដល់សេដ្ឋកិច្ច សង្គម និងប្រជាជាតិ ព្រមទាំងរក្សាឱ្យបានជាអប្បបរមានូវផលប៉ះពាល់ដល់បរិស្ថាននិងសង្គម។

កម្ពុជាត្រូវបានគេចាត់ទុកថាជាប្រទេសដែលមានធនធានរ៉ែច្រើនប្រភេទ រាជរដ្ឋាភិបាលកំពុងខិតខំជាជំហានៗ ដើម្បីកំណត់ឱ្យបានជាក់លាក់នូវទំហំនិងបរិមាណធនធានរ៉ែទាំងនោះ។ ការសិក្សាភូគព្ភសាស្ត្រនិងធនធានរ៉ែត្រូវបានធ្វើតាំងតែពីជិត១៥០ឆ្នាំមុន ប៉ុន្តែដោយសារការឆ្លងកាត់សង្គ្រាមស៊ីវិលអស់រយៈពេលជិត ៣០ឆ្នាំ បានធ្វើឱ្យទិន្នន័យដែលបានកត់ត្រាទុកនាសម័យកាលនោះបានបាត់បង់ស្ទើរតែទាំងស្រុង។ យោងតាមឯកសារធនធានរ៉ែដែលចងក្រងដោយការិយាល័យសិក្សាស្រាវជ្រាវភូគព្ភសាស្ត្រនិងធនធានរ៉ែប្រទេសបារាំង (BRGM) ក្នុងដើមទសវត្សទី៨នៃសតវត្សទី២០និងឯកសារធនធានរ៉ែកម្ពុជា (Atlas of Mineral Resources of Cambodia Volume 10) ដែលចងក្រងនៅក្នុងឆ្នាំ១៩៩៣ ដោយស្នងការសេដ្ឋកិច្ចនិងសង្គមសម្រាប់អាស៊ីនិងប៉ាស៊ីហ្វិកនៃអង្គការសហប្រជាជាតិ (UNESCAP) និងការសិក្សាថ្មីៗទៀតក្នុងអំឡុងទសវត្សទី៨និង៩នៃសតវត្សទី២០ បានបង្ហាញនូវវត្តមានធនធានរ៉ែប្រកបដោយសក្តានុពលក្នុងប្រទេសកម្ពុជា ដែលជាបច្ច័យដ៏សំខាន់ក្នុងការទាក់ទាញចំណាប់អារម្មណ៍របស់ធុរជនក្នុងវិស័យរ៉ែ។

ក្រោយពេលដែលប្រទេសកម្ពុជាបានទទួលនូវសុខសន្តិភាពពេញលេញក្រោមនយោបាយឈ្នះឈ្នះរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**នាឆ្នាំ១៩៩៨ វិស័យរ៉ែបានចាប់ផ្តើមមានសន្ទុះរីកចម្រើនជាលំដាប់ ដែលតម្រូវឱ្យមានការរៀបចំដាក់ចេញនូវគោលនយោបាយដ៏ជាក់លាក់មួយក្នុងគោលដៅតម្រង់ទិសការអភិវឌ្ឍធនធានរ៉ែដ៏មានសក្តានុពលនិងឆ្លើយតបនឹងបទពិសោធនៅមានកម្រិតរបស់កម្ពុជាលើវិស័យនេះ។

រ៉ែសំណង់បានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្គត់ផ្គង់វត្ថុធាតុដើមមានថ្មសំណង់ ក្រួស ខ្សាច់ ឡាតេរីតសម្រាប់បម្រើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ស្ពាន វារីអគ្គិសនី ទំនប់ធារាសាស្ត្រ និងសំណង់នានាទូទាំងប្រទេស។ ចុងឆ្នាំ២០១៧មានអាជ្ញាបណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្មប្រមាណ២៦០បានផ្តល់ឱ្យ

ដល់អាជីវករធ្វើអាជីវកម្មធនធានរ៉ែសំណង់លើផ្ទៃដីប្រមាណជាង៦ ០០០ហិកតា ដោយប្រើកម្លាំងពលកម្មជាង៥ ០០០នាក់ និងមានទុនវិនិយោគសរុបប្រមាណ៣៣៥ ០០០ ០០០ដុល្លារសហរដ្ឋអាមេរិក។

ឯផ្នែករ៉ែឧស្សាហកម្មក៏បានរីកចម្រើនគួរឱ្យកត់សម្គាល់ផងដែរ ក្នុងនោះការធ្វើអាជីវកម្មថ្មកំបោរសម្រាប់ផ្គត់ផ្គង់ដល់រោងចក្រផលិតស៊ីម៉ងត៍ក្នុងស្រុកបានកើនឡើងយ៉ាងខ្លាំង។ បច្ចុប្បន្ននេះ មានរោងចក្រផលិតស៊ីម៉ងត៍ចំនួន៥កំពុងដំណើរការដែលអាចមានលទ្ធភាពផ្គត់ផ្គង់ស៊ីម៉ងត៍ប្រមាណ៧ ០០០ ០០០តោនក្នុងមួយឆ្នាំ ឆ្លើយតបបាននឹងតម្រូវការសាងសង់និងកាត់បន្ថយបានជាអតិបរមានូវការនាំចូលផលិតផលស៊ីម៉ងត៍ពីក្រៅប្រទេស។ ជាងនេះទៅទៀត អាជីវកម្មថ្មកំបោរនេះក៏ត្រូវបានប្រើប្រាស់ជាវត្ថុធាតុដើមសម្រាប់ផ្គត់ផ្គង់ដល់រោងចក្រអគ្គិសនីនិងដល់អាជីវកម្មផលិតចំណីសត្វផងដែរ។

ចំពោះរ៉ែលោហៈវិញមានអាជ្ញាបណ្ណស្វែងរុករកធនធានរ៉ែចំនួន៥៤អាជ្ញាបណ្ណ គិតត្រឹមចុងឆ្នាំ២០១៧ ត្រូវបានផ្តល់ដល់វិនិយោគិនទាំងក្នុងស្រុកនិងក្រៅស្រុក ដើម្បីធ្វើការសិក្សាស្រាវជ្រាវរ៉ែលោហៈដែលរួមមានរ៉ែដែក មាស ទង់ដែង និងរ៉ែបុកស៊ីត។ ដោយឡែកអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែចំនួន២៧ ក៏បានផ្តល់ដល់វិនិយោគិនសម្រាប់ការធ្វើអាជីវកម្មរ៉ែដែក មាស ត្បូងថ្ម និងខ្សាច់ស៊ីលីកា ដែលក្នុងនោះឧស្សាហកម្មអាជីវកម្មរ៉ែមាសខ្នាតមធ្យមចំនួន១ កំពុងដំណើរការសាងសង់រោងចក្រដែលគ្រោងនឹងចាប់ផ្តើមអាជីវកម្មរ៉ែមាសនាឆ្នាំ២០១៨នេះ។ ទុនវិនិយោគសរុបសម្រាប់រ៉ែលោហៈនេះមានចំនួនប្រមាណ៧៣៣ ០០០ ០០០ដុល្លារសហរដ្ឋអាមេរិក ដោយប្រើកម្លាំងពលកម្មចំនួនប្រមាណជាង១ ៥០០នាក់។

អាស្រ័យដោយការកែទម្រង់លើវិធានការប្រមូលចំណូលពីវិស័យរ៉ែនាឆ្នាំ២០១៥ បានធ្វើឱ្យចំណូលពីវិស័យរ៉ែក្នុងឆ្នាំ២០១៦ មានការកើនឡើងរហូតដល់ជាង៥២ ០០០ ០០០ ០០០រៀល (ជាងដប់បីលានដុល្លារសហរដ្ឋអាមេរិក) ធៀបនឹងឆ្នាំ២០១៣ ដែលមានតែជាង៧ ០០០ ០០០ ០០០ រៀល (ជិតពីរលានដុល្លារសហរដ្ឋអាមេរិក) តែប៉ុណ្ណោះ។

ការដាក់ចេញនូវគោលនយោបាយជាតិស្តីពីធនធានរ៉ែនេះនឹងជួយតម្រង់ទិសវិស័យរ៉ែឱ្យមានការអភិវឌ្ឍស្របតាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាល បង្កើតនូវបរិយាកាសទាក់ទាញការវិនិយោគទាំងក្នុងនិងក្រៅប្រទេស និងធានាឱ្យការអភិវឌ្ឍឧស្សាហកម្មរ៉ែនេះប្រព្រឹត្តទៅប្រកបដោយចីរភាពនិងការទទួលខុសត្រូវខ្ពស់ដោយផ្តោតការយកចិត្តទុកដាក់លើបច្ច័យធំៗបីជាចម្បងគឺសេដ្ឋកិច្ច សង្គម និងបរិស្ថាន។

គោលនយោបាយជាតិស្តីពីធនធានរ៉ែនេះក៏បានរៀបរៀងឡើងស្របនឹងផែនការសកម្មភាពសហប្រតិបត្តិការរ៉ែអាស៊ានឆ្នាំ២០១៦-២០២៥ (ASEAN Minerals Cooperation Action Plan-AMCAP 2016-2025) ក្នុងគោលបំណងធានាឱ្យបាននូវការអភិវឌ្ឍវិស័យរ៉ែប្រកបដោយចីរភាពនិងសម្រេចឱ្យបាននូវសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់អាស៊ានតាមគោលដៅឆ្នាំ២០២៥ ដែលបានអនុម័តដោយកិច្ចប្រជុំរដ្ឋមន្ត្រីរ៉ែអាស៊ាន (ASEAN Ministerial Meeting on Minerals-AMMin)។

គោលនយោបាយជាតិស្តីពីធនធានរ៉ែនេះអះអាងនូវតួនាទីគាំទ្រនិងបង្ហាញនូវភាពទន់ភ្លន់របស់រាជរដ្ឋាភិបាលក្នុងការជំរុញឧស្សាហកម្មរ៉ែ ឧស្សាហកម្មដែលប្រើប្រាស់វត្ថុធាតុដើមពីធនធានរ៉ែ និងការធ្វើពាណិជ្ជកម្មផលិតផលរ៉ែ។ ការអភិវឌ្ឍធនធានមនុស្ស ការអភិវឌ្ឍសហគមន៍មូលដ្ឋាន ការលើកទឹកចិត្តឱ្យប្រើកម្លាំងពលកម្ម

ក្នុងតំបន់និងបញ្ហាយេនឌ័រក្នុងវិស័យរ៉ែក៏ត្រូវបានផ្តល់ការយកចិត្តទុកដាក់ផងដែរ។ គោលនយោបាយជាតិស្តីពីធនធានរ៉ែនេះតំណាងឱ្យរបត់ដ៏ហានដ៏សំខាន់ក្នុងការរៀបចំវិស័យរ៉ែឱ្យក្លាយទៅជាផ្នែកមួយនៃខឿនសេដ្ឋកិច្ចជាតិដែលនឹងដើរតួនាទីរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា ផ្តល់នូវវិបុលភាពដល់ប្រជាពលរដ្ឋ និងសម្រេចបាននូវការកាត់បន្ថយភាពក្រីក្រស្របតាមទិសដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា។

## ២- ចក្ខុវិស័យ

ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលចំពោះវិស័យរ៉ែគឺ **"អភិវឌ្ឍន៍ធនធានរ៉ែដើម្បីផលប្រយោជន៍សេដ្ឋកិច្ចនិងសង្គមប្រកបដោយអភិបាលកិច្ចល្អនិងការទទួលខុសត្រូវខ្ពស់ផ្នែកបរិស្ថាន"**។

## ៣- គោលបំណងនិងគោលដៅ

គោលនយោបាយនេះមានគោលបំណង៖

១- គ្រប់គ្រងនិងអភិវឌ្ឍធនធានរ៉ែប្រកបដោយចីរភាព។

២- ផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋនិងសហគមន៍រ៉ែ។

៣- ផ្គត់ផ្គង់វត្ថុធាតុដើមដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនិងសំណង់។

៤- បង្កើតប្រភពចំណូលថ្មីសម្រាប់ជាតិ។

ដើម្បីអនុវត្តឱ្យបានសម្រេចនូវគោលបំណងខាងលើ គោលដៅចំនួន៥ត្រូវបានដាក់ចេញរួមមាន៖

គោលដៅទី១ : ពង្រឹងតួនាទីស្ថាប័នរដ្ឋក្នុងការគ្រប់គ្រងនិងការអភិវឌ្ឍធនធានរ៉ែ

គោលដៅទី២ : ជំរុញការធ្វើប្រតិបត្តិការធនធានរ៉ែប្រកបដោយចីរភាពនិងការទទួលខុសត្រូវ

គោលដៅទី៣ : អភិវឌ្ឍធនធានរ៉ែនិងសហគមន៍

គោលដៅទី៤ : អភិវឌ្ឍសិប្បកម្មរ៉ែនិងអាជីវកម្មរ៉ែខ្នាតតូច

គោលដៅទី៥ : ធនធានរ៉ែនិងការនាំចេញ

## ៤- យុទ្ធសាស្ត្រនិងផែនការសកម្មភាព

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ រាជរដ្ឋាភិបាលបានកំណត់នូវយុទ្ធសាស្ត្រសំខាន់ៗតាមបណ្តាគោលដៅដូចតទៅ៖

### គោលដៅទី១- ពង្រឹងតួនាទីស្ថាប័នរដ្ឋក្នុងការគ្រប់គ្រងនិងការអភិវឌ្ឍធនធានរ៉ែ

**១- ការរៀបចំច្បាប់និងបទប្បញ្ញត្តិនានា**

តួនាទីរបស់រដ្ឋក្នុងការគ្រប់គ្រងការអភិវឌ្ឍធនធានរ៉ែត្រូវបានកំណត់នៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែឆ្នាំ២០០១។ ច្បាប់នេះបានកំណត់ពីតួនាទីរបស់រាជរដ្ឋាភិបាលកម្ពុជាដែលមានក្រសួងទទួលបន្ទុកវិស័យរ៉ែជាស្ថាប័នអនុវត្តក្នុងការទទួលខុសត្រូវអភិវឌ្ឍធនធានរ៉ែចាប់តាំងពីដំណាក់កាលបុរេសនារហូតដល់ការធ្វើផលិតកម្ម អាជីវកម្ម និងពាណិជ្ជកម្មផលិតផលធនធានរ៉ែ។ ដើម្បីសម្រេចបាននូវការទទួលខុសត្រូវនេះ ចាំបាច់ត្រូវធ្វើការបំពេញបន្ថែមនូវច្បាប់និងបទប្បញ្ញត្តិនានាឱ្យមានសុខដុមនីយកម្មជាមួយនឹងគោលនយោបាយជាតិស្តីពីធនធានរ៉ែនេះនិងជាមួយនឹងច្បាប់និងបទប្បញ្ញត្តិដទៃៗទៀត។

**ផែនការសកម្មភាព** :

ក- ជំរុញការរៀបចំក្រមស្តីពីធនធានរ៉ែដែលរួមមានបញ្ញត្តិស្តីពីការគ្រប់គ្រងប្រតិបត្តិការធនធានរ៉ែ សុវត្ថិភាពអណ្តូងរ៉ែ និងមន្ត្រីអធិការកិច្ចធនធានរ៉ែព្រមទាំងបទប្បញ្ញត្តិនិងគោលការណ៍នានាក្នុងការអនុវត្តច្បាប់។

ខ- ពិនិត្យឡើងវិញនូវបទប្បញ្ញត្តិនានាដែលទាក់ទងជាមួយនឹងវិស័យរ៉ែនិងរៀបចំបំពេញបន្ថែមចំណុចខ្វះខាត សំដៅធានាប្រសិទ្ធភាពក្នុងការគ្រប់គ្រងវិស័យរ៉ែនិងធានាដល់ការប្រតិបត្តិនូវអភិបាលកិច្ចល្អដែលជាស្នូលនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល។

គ- រៀបចំបទប្បញ្ញត្តិស្តីពីការគ្រប់គ្រងទិន្នន័យភូគព្ភសាស្ត្រនិងសំណាកភូគព្ភសាស្ត្រ។

ឃ- រៀបចំបទប្បញ្ញត្តិដើម្បីធានានូវការប្រមូលចំណូលពីវិស័យរ៉ែប្រកបដោយតម្លាភាពនិងប្រសិទ្ធភាព។

**២- ការពង្រឹងសមត្ថភាពមន្ត្រីនិងការកសាងធនធានមនុស្ស**

ការពង្រឹងតួនាទីស្ថាប័នរដ្ឋត្រូវផ្សារភ្ជាប់នឹងការពង្រឹងសមត្ថភាពដល់មន្ត្រីដែលអនុវត្តច្បាប់និងបទប្បញ្ញត្តិទាំងនោះ។ ការពង្រឹងនិងបង្កើនសមត្ថភាពមន្ត្រីត្រូវធ្វើតាមផែនការជាប្រចាំសំដៅធានាឱ្យមន្ត្រីបម្រើវិស័យរ៉ែមានសមត្ថភាពក្នុងការគ្រប់គ្រងច្បាស់លាស់ទាំងផ្នែកបច្ចេកទេសនិងទាំងផ្នែកហិរញ្ញវត្ថុ។

ការកសាងធនធានមនុស្សផ្នែកវិស័យភូគព្ភសាស្ត្រនិងវិស្វកម្មរ៉ែ គឺជាតម្រូវការចាំបាច់សម្រាប់បម្រើឱ្យវិស័យរ៉ែរបស់កម្ពុជានាពេលបច្ចុប្បន្នក៏ដូចជាទៅអនាគត។ ការបណ្តុះបណ្តាលធនធានមនុស្សឱ្យមានជំនាញពិតប្រាកដនឹងរួមចំណែកជំរុញការអភិវឌ្ឍវិស័យរ៉ែ បង្កើនផលិតភាព ស្រូបយកកម្លាំងពលកម្មក្នុងស្រុក និងកាត់បន្ថយបានជាអតិបរមានូវអ្នកជំនាញការបរទេស។

**ផែនការសកម្មភាព** :

ក- ពង្រឹងសមត្ថភាពមន្ត្រីក្នុងការត្រួតពិនិត្យក្រុមហ៊ុនរ៉ែទាំងផ្នែកបច្ចេកទេសនិងទាំងផ្នែកហិរញ្ញវត្ថុ។

ខ- ពង្រឹងសមត្ថភាពមន្ត្រីក្នុងការធ្វើអធិការកិច្ចការដ្ឋានអាជីវកម្មធនធានរ៉ែលើសុវត្ថិភាពការងារនិងសុខភាព។

គ- ពង្រឹងយន្តការនិងសមត្ថភាពមន្ត្រីក្នុងការគៀរគរប្រមូលចំណូលពីវិស័យរ៉ែ។

ឃ- កសាងសមត្ថភាពមន្ត្រីលើផ្នែកផែនទីភូគព្ភសាស្ត្រ ភូគព្ភសាស្ត្របរិស្ថាន និងការគ្រប់គ្រងនិងដំណើរការមន្ទីរពិសោធន៍។

ង- ពិនិត្យរៀបចំបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលធនធានមនុស្សក្នុងវិស័យរ៉ែរយៈពេលខ្លីនិងមធ្យមសម្រាប់បណ្តុះបណ្តាលកម្មករជំនាញនិងអ្នកបច្ចេកទេស។

ច- លើកផែនការតម្រូវការធនធានមនុស្សរយៈពេល៥ឆ្នាំម្តង ដោយសហការជាមួយស្ថាប័នអប់រំដើម្បីបញ្ចូលក្នុងកម្មវិធីបណ្តុះបណ្តាលចំពោះអ្នកបច្ចេកទេសជាន់ខ្ពស់និងវិស្វករជំនាញ។

ឆ- សហការជាមួយនឹងប្រទេសក្នុងតំបន់និងដៃគូអភិវឌ្ឍនានាដើម្បីស្នើសុំការបណ្តុះបណ្តាលរយៈពេលវែងនិងលើជំនាញបច្ចេកទេសបន្ថែម ក្នុងគោលដៅកាត់បន្ថយឱ្យបានជាអតិបរមានូវការប្រើបុគ្គលិកនិងអ្នកជំនាញការបរទេស។

**៣- ការធ្វើសារពើភណ្ឌធនធានរ៉ែ**

ក្នុងទិសដៅជំរុញការទាក់ទាញវិនិយោគបរទេសនិងក្នុងស្រុក ការធ្វើសារពើភណ្ឌធនធានរ៉ែគឺជាប្រការដ៏សំខាន់បំផុតដើម្បីកំណត់អំពីអត្តសញ្ញាណសក្តានុពលធនធានរ៉ែដែលជាជំហានឆ្ពោះទៅរកការបង្កើតនូវតំបន់ការពារធនធានរ៉ែនិងតំបន់បម្រុងទុកធនធានរ៉ែ។ ការកំណត់បាននូវតំបន់ធនធានរ៉ែនឹងជួយឱ្យរដ្ឋអាចដាក់ចេញនូវវិធានការសំខាន់ៗដើម្បីការពារតំបន់ដែលមានសក្តានុពលធនធានរ៉ែ លោហៈធាតុកម្រ លោហៈធាតុដែលមានគ្រោះថ្នាក់។ល។ និងអាចវិភាគទៅលើអត្ថប្រយោជន៍សេដ្ឋកិច្ចនៃធនធានរ៉ែនោះជាមុន មុននឹងធ្វើការសម្រេចលើការស្នើសុំវិនិយោគ។ ការដេញថ្លៃចំពោះតំបន់ដែលមានសក្តានុពលធនធានរ៉ែជាក់លាក់នឹងត្រូវអនុវត្ត។

**ផែនការសកម្មភាព** :

ក- ជំរុញរៀបចំសារពើភណ្ឌជាតិធនធានរ៉ែដោយបង្កើតឱ្យមានជាឃ្លាំងទិន្នន័យ (Data Bank) និងផែនទីភូគព្ភសាស្ត្រនិងធនធានរ៉ែផ្សេងៗ តាមរយៈការកំណត់អត្តសញ្ញាណធនធានរ៉ែ តំបន់ធនធានរ៉ែ និងទិន្នន័យជម្រករ៉ែ។ សារពើភណ្ឌជាតិធនធានរ៉ែត្រូវបានបង្កើតដោយផ្អែកលើប្រភពជាមូលដ្ឋានចំនួន៤គឺៈ

ទី១- ទិន្នន័យនិងព័ត៌មានដែលមានស្រាប់ក្នុងប្រទេស។

ទី២- ទិន្នន័យដែលទទួលបានថ្មីៗពីវិនិយោគិនក្នុងប្រតិបត្តិការធនធានរ៉ែតាមដំណាក់កាលនីមួយៗ។

ទី៣- ទិន្នន័យដែលបានមកពីការអង្កេតភូគព្ភសាស្ត្រ គីមីភូគព្ភសាស្ត្រ រូបភូគព្ភសាស្ត្រ និងតាមវិធីសាស្ត្រផ្សេងៗទៀតដែលដឹកនាំធ្វើដោយក្រសួងទទួលបន្ទុកវិស័យរ៉ែនិងបានមកពីគម្រោងសហប្រតិបត្តិការនានា។

ទី៤- ការសិក្សាស្រាវជ្រាវនិងបម្លាស់ប្តូរព័ត៌មានទិន្នន័យជាមួយនឹងប្រទេសជិតខាង។

ខ- ដំណើរការ (Process) វិភាគ បកស្រាយទិន្នន័យភូគព្ភវិទ្យាសាស្ត្រ (Geoscientific data) និងធ្វើការវាយតម្លៃធនធានរ៉ែ (Mineral Resources Assessment)។

គ- ធ្វើបច្ចុប្បន្នកម្មទិន្នន័យ ផែនទីភូគព្ភសាស្ត្រ និងផែនទីធនធានរ៉ែជាប្រចាំ។

ឃ- កំណត់បង្កើតតំបន់ធនធានរ៉ែដែលក្នុងនោះបែងចែកជាតំបន់ការពារធនធានរ៉ែនិងតំបន់បម្រុងទុកធនធានរ៉ែ។ តំបន់ការពារធនធានរ៉ែគឺជាតំបន់ដែលសន្ទស្សន៍រ៉ែត្រូវបានស្រាវជ្រាវរកឃើញ ឬជាតំបន់ដែលរចនាសម្ព័ន្ធភូគព្ភសាស្ត្របានបង្ហាញអំពីលទ្ធភាពនៃវត្តមានធនធានរ៉ែ រីឯតំបន់បម្រុងទុកធនធានរ៉ែគឺជាតំបន់ដែលជម្រករ៉ែត្រូវបានស្រាវជ្រាវរកឃើញ ហើយព័ត៌មាននិងទិន្នន័យភូគព្ភសាស្ត្រអំពីសក្តានុពលធនធានរ៉ែត្រូវបានកំណត់។

ង- រៀបចំបង្កើតមន្ទីរពិសោធន៍រ៉ែ ឃ្លាំងតម្កល់សំណាកគំរូរ៉ែ និងសារមន្ទីរភូគព្ភសាស្ត្រជាតិ។

ច- បង្កើតបណ្ណសារដ្ឋានភូគព្ភសាស្ត្រ (Geological Archives) ដើម្បីរក្សាទុកឯកសារនិងសម្រាប់ការសិក្សាស្រាវជ្រាវ។

ឆ- ប្រមូលចងក្រងព័ត៌មានភូគព្ភសាស្ត្រដែលមានស្រាប់និងធ្វើការចងក្រងផែនទីតិចតួនិចភូគព្ភសាស្ត្រ ១:៥០០ ០០០ ក្នុងតំបន់នៃប្រទេសទាំងមូល។

ជ- រៀបចំគោលការណ៍ណែនាំក្រុមហ៊ុនរ៉ែក្នុងការផ្តល់របាយការណ៍បច្ចេកទេសដើម្បីងាយស្រួលក្នុងការចងក្រងវិភាគទិន្នន័យនៃការស្វែងរុករកធនធានរ៉ែថ្មីៗ។

ឈ- លើកទឹកចិត្តការសិក្សាស្រាវជ្រាវរ៉ែវិទ្យុសកម្មដើម្បីឱ្យដឹងអំពីសក្តានុពលដោយសហការជាមួយនឹងដៃគូអភិវឌ្ឍឬស្ថាប័នជំនាញអន្តរជាតិ។

**៤- អភិបាលកិច្ចល្អនិងការគ្រប់គ្រងប្រកបដោយគណនេយ្យភាពនិងតម្លាភាព**

អភិបាលកិច្ចល្អនិងការគ្រប់គ្រងប្រកបដោយគណនេយ្យភាពនិងតម្លាភាព គឺជាគន្លឹះក្នុងការបង្កើតជំនឿទុកចិត្តរបស់វិនិយោគិននិងភាពទទួលយកបានដោយប្រជាពលរដ្ឋក្នុងតំបន់អាជីវកម្មធនធានរ៉ែ។ សកម្មភាពរបស់ក្រសួងទទួលបន្ទុកវិស័យរ៉ែដែលជាអង្គភាពទទួលខុសត្រូវក្នុងការអភិវឌ្ឍវិស័យរ៉ែរួមនឹងក្រសួងពាក់ព័ន្ធដទៃទៀតត្រូវតែឆ្លើយតបទៅនឹងបញ្ហាដែលបានកើតចេញឡើងដោយសារការអភិវឌ្ឍរ៉ែ។

គោលការណ៍នៃការពិគ្រោះយោបល់ដោយចំហជាមួយនឹងភាគីពាក់ព័ន្ធដែលរួមមានក្រុមហ៊ុនប្រតិបត្តិការធនធានរ៉ែ ប្រជាពលរដ្ឋក្នុងសហគមន៍ និងរដ្ឋបាលថ្នាក់ក្រោមជាតិនឹងផ្តល់នូវកាលានុវត្តភាពដល់គ្រប់ភាគីទាំងអស់ក្នុងការផ្តល់នូវមតិយោបល់ស្ថាបនាដើម្បីចូលរួមដោះស្រាយនូវបញ្ហាដែលជាផលប្រយោជន៍រួម។ ប្រការនេះនឹងធានាឱ្យប្រតិបត្តិការធនធានរ៉ែប្រព្រឹត្តទៅដោយរលូន ដោយមានការគាំទ្រសហការពីគ្រប់ភាគីពាក់ព័ន្ធក្នុងវិស័យរ៉ែ។

**ផែនការសកម្មភាព** :

ក- អនុវត្តនូវអភិបាលកិច្ចល្អចាប់តាំងពីការចាប់ផ្តើមជំហានដំបូងនៃការសិក្សាអង្កេតភូគព្ភសាស្ត្ររហូតដល់ដំណាក់កាលអាជីវកម្ម។

ខ- កំណត់រៀបចំជាគោលការណ៍សំខាន់ៗនៃអភិបាលកិច្ចល្អ មានជាអាទិ៍ ការធ្វើរបាយការណ៍ ការធ្វើអធិការកិច្ច ការបញ្ជ្រាបព័ត៌មានទៅប្រជាពលរដ្ឋ ការធ្វើទំនាក់ទំនង និងនីតិវិធីនៃការពិគ្រោះយោបល់រវាងភាគីពាក់ព័ន្ធ។ល។

គ- គ្រប់គ្រង ប្រមូល និងប្រើប្រាស់ចំណូលធនធានរ៉ែប្រកបដោយតម្លាភាពស្របតាមគោលការណ៍នៃច្បាប់។

ឃ- បង្កើតយន្តការគៀរគរប្រមូលចំណូលធនធានរ៉ែដែលជាយន្តការចម្បងក្នុងការអនុវត្តគោលនយោបាយប្រកបដោយតម្លាភាពនិងគណនេយ្យភាព។ យន្តការនេះតម្រូវឱ្យមានមន្ត្រីដែលមាននីតិសម្បទាជានគរបាលយុត្តិធម៌ដែលអាចធ្វើការផាកពិន័យ គៀរគរចំណូលចូលរដ្ឋ

និង/ឬកសាងសំណុំរឿងទៅតុលាការលើបទល្មើសធនធានរ៉ែដែលប៉ះពាល់ដល់បរិស្ថាន សង្គម និងចំណូលជាតិ។

ង- បង្កើតយន្តការពិគ្រោះយោបល់ក្នុងន័យផ្តល់នូវតម្លាភាពនិងឱកាសចូលរួមពីប្រជាពលរដ្ឋក្នុងសហគមន៍ដែលរងផលប៉ះពាល់ យន្តការនេះនឹងត្រូវអនុវត្តមុនពេលផ្តល់អាជ្ញាបណ្ណធនធានរ៉ែ សំដៅទទួលយកមតិយោបល់ស្ថាបនា ចូលរួមពិភាក្សាដោះស្រាយបញ្ហាប្រឈមដែលអាចនឹងកើតមាននិងប្រមូលធាតុចូលក្នុងការសម្រេចផ្តល់អាជ្ញាបណ្ណ។

ច- បង្កើតយន្តការផ្សព្វផ្សាយព័ត៌មានរ៉ែដល់សាធារណជនតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គមនិងតាមរយៈព្រឹត្តិបត្រព័ត៌មានវិស័យរ៉ែឱ្យបានទៀងទាត់។

## ៥- ការជំរុញវិនិយោគ

ជំរុញការវិនិយោគគឺជាទិសដៅចម្បងរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍវិស័យរ៉ែ។ ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជាមានលក្ខណៈអនុគ្រោះបំផុតដល់វិនិយោគិនក្នុងនិងក្រៅស្រុក ដោយអនុញ្ញាតឱ្យក្រុមហ៊ុនបរទេសមានសិទ្ធិកាន់កាប់ភាគហ៊ុន១០០ភាគរយក្នុងប្រតិបត្តិការធុរកិច្ចរបស់ខ្លួនរាប់ទាំងវិស័យរ៉ែនេះផង។ រាជរដ្ឋាភិបាលបានចាត់ទុកវិស័យឯកជនជាដៃគូអភិវឌ្ឍសេដ្ឋកិច្ចដ៏សំខាន់ក្នុងការជួយជំរុញកំណើនសេដ្ឋកិច្ចជាតិ ការស្រូបកម្លាំងពលកម្មក្នុងស្រុក និងការចូលរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។ ក្នុងបរិបទនេះ រាជរដ្ឋាភិបាលនឹងសម្រួលគ្រប់មធ្យោបាយដល់វិនិយោគិនទាំងក្នុងស្រុកទាំងបរទេសក្នុងការស្វែងរកកាលានុវត្តភាពវិនិយោគនៅកម្ពុជា ព្រមទាំងបង្កើននូវជំនឿទុកចិត្តដល់វិនិយោគិនក្នុងការបណ្តាក់ទុនក្នុងវិស័យរ៉ែនេះ។ រាជរដ្ឋាភិបាលនឹងរៀបចំរបបពន្ធអាករពិសេសដែលមានភាពប្រកួតប្រជែងជាអន្តរជាតិ ដើម្បីជំរុញនិងអភិវឌ្ឍវិស័យរ៉ែ។ របបពន្ធអាករពិសេសនេះនឹងមិនបង្កឱ្យរាំងស្ទះដល់ការអភិវឌ្ឍវិស័យរ៉ែទេ ផ្ទុយទៅវិញនឹងជួយជំរុញឱ្យកាន់តែមានប្រសិទ្ធភាពក្នុងការអភិវឌ្ឍវិស័យនេះ។

**ផែនការសកម្មភាព :**

ក- ផ្តល់នូវទិន្នន័យបឋមតាមរយៈការផ្សព្វផ្សាយនិងដាក់ក្នុងគេហទំព័រដើម្បីធ្វើការទាក់ទាញការវិនិយោគក្នុងវិស័យរ៉ែនិងជួយសម្រួលដល់វិនិយោគិនក្នុងដំណាក់កាលសិក្សាដំបូង (Reconnaissance) ឬបុរេសនា (Prospecting) ។

ខ- ផ្តល់នូវទិន្នន័យនិងព័ត៌មានលំអិតដល់វិនិយោគិនដែលមានសក្តានុពល (Potential Investors) ដោយឈរលើមូលដ្ឋានបង់ថ្លៃ។

គ- អនុវត្តនូវគោលការណ៍ "អ្នកមកមុនទទួលបានសេវាមុន" (First Come First Serve Basis)។

ឃ- ផ្តល់នូវការធានាដល់វិនិយោគិនដែលទទួលបានសិទ្ធិស្វែងរុករកធនធានរ៉ែក្នុងតំបន់សម្បទានធនធានរ៉ែនូវសិទ្ធិទទួលបានអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែស្របតាមគោលការណ៍នៃច្បាប់និងបទប្បញ្ញត្តិដែលទាក់ទងនឹងវិស័យរ៉ែ។

ង- រៀបចំរបបពន្ធអាករពិសេសសម្រាប់វិស័យរ៉ែដោយឈរលើគោលការណ៍យុត្តិធម៌ តម្លាភាព ដើម្បីរក្សាស្ថិរភាពនៃចំណូលនិងភាពប្រកួតប្រជែងដោយយកចិត្តទុកដាក់ជាពិសេសចំពោះ

ការប្រើប្រាស់ធនធានរ៉ែធ្វើជាវត្ថុធាតុដើមសម្រាប់បម្រើឱ្យឧស្សាហកម្មក្នុងស្រុកនិងការកែច្នៃផលិតផលរ៉ែសំដៅបង្កើននូវតម្លៃបន្ថែម។ រៀបចំនីតិវិធីប្រមូលចំណូលសួយសារនិងកំណត់នូវអត្រាសួយសារសមស្របតាមប្រភេទរ៉ែនីមួយៗ។

## គោលដៅទី២- ជំរុញការធ្វើប្រតិបត្តិការធនធានរ៉ែប្រកបដោយចីរភាពនិងការទទួលខុសត្រូវ

### ១- ការអនុវត្តអភិក្រមអភិវឌ្ឍប្រកបដោយចីរភាព

គោលដៅដ៏ចម្បងនៃការអភិវឌ្ឍធនធានរ៉ែគឺការធានាឱ្យវិស័យនេះអភិវឌ្ឍប្រកបដោយចីរភាពនិងការទទួលខុសត្រូវ។ ក្នុងនោះបញ្ហាសេដ្ឋកិច្ច សង្គម និងបរិស្ថានគឺជាកត្តាគន្លឹះដែលត្រូវតែពិនិត្យពិចារណាឱ្យបានហ្មត់ចត់នៅក្នុងការសម្រេចអនុញ្ញាតឱ្យវិនិយោគ។ សមាហរណកម្មធាតុដ៏សំខាន់ទាំងបីនេះ មុននឹងធ្វើការសម្រេចឱ្យវិនិយោគគឺជាប្រការចាំបាច់ដែលត្រូវយកចិត្តទុកដាក់វាយតម្លៃឱ្យបានត្រឹមត្រូវពេញលេញពុំនោះសោតវានឹងក្លាយទៅជាបញ្ហាប្រឈមដែលរាំងស្ទះដល់ការអភិវឌ្ឍធនធានរ៉ែប្រកបដោយចីរភាព។

ការវិនិយោគលើវិស័យរ៉ែគឺជាការវិនិយោគដែលមានហានិភ័យខ្ពស់ ការធ្វើបុរេសនារ៉ែចំនួន១០០គម្រោងគឺមានតែមួយគម្រោងទេដែលអាចឈានទៅដល់ការស្វែងរុករក ហើយក្នុងការធ្វើបុរេសនារ៉ែចំនួន១០០០គម្រោងគឺមានតែមួយគម្រោងប៉ុណ្ណោះដែលអាចឈានទៅដល់ការធ្វើអាជីវកម្មធនធានរ៉ែ។ ក្រៅពីការចំណាយពេលយូរឆ្នាំក្នុងការសិក្សាស្រាវជ្រាវ វិស័យនេះទាមទារនូវការចំណាយទុនដ៏ច្រើន មុននឹងអាចដំណើរការផលិតកម្មរ៉ែបាន។ បញ្ហាប្រឈមដ៏សំខាន់មួយទៀតរបស់វិស័យរ៉ែគឺលក្ខណៈខួបនៃទីផ្សារទំនិញ (The Cyclical Nature of Commodity Markets) ដែលជាហានិភ័យដែលតែងតែកើតមានក្នុងទីផ្សារសេដ្ឋកិច្ចពិភពលោក។

ហេតុនេះរាជរដ្ឋាភិបាលនឹងរៀបចំឱ្យបានច្បាស់លាស់នូវគោលការណ៍សំខាន់ៗមួយចំនួនដែលរួមមានអភិក្រមឆ្លើយតបប្រកបដោយការទទួលខុសត្រូវ ផែនការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ តួនាទីដែលមិនមែនជាបញ្ញត្តិកម្ម (Non-Regulatory Roles) និងយន្តការនៃការការពារការបំពុលបរិស្ថាន ក្នុងទិសដៅកាត់បន្ថយឱ្យបានជាអតិបរមានូវហានិភ័យនៃបញ្ហាប្រឈមទាំងឡាយខាងលើនេះ។

**ផែនការសកម្មភាព :**

ក- រៀបចំសេចក្ដីសម្រេចដោយសមាហរណកម្មបញ្ហាបរិស្ថាន សេដ្ឋកិច្ច និងសង្គម ដើម្បីធានាឱ្យការអភិវឌ្ឍធនធានរ៉ែដំណើរការប្រកបដោយចីរភាព។

ខ- រៀបចំអភិក្រមឆ្លើយតបប្រកបដោយការទទួលខុសត្រូវ (Responsive Approach) ដែលក្នុងនោះត្រូវមានយន្តការដោះស្រាយឱ្យបានទាន់ពេលវេលាចំពោះសំណូមពររបស់អ្នកពាក់ព័ន្ធទាំងអស់ (ក្រុមហ៊ុន ប្រជាជនក្នុងតំបន់រ៉ែនិងជិតខាងតំបន់រ៉ែ និងរដ្ឋបាលថ្នាក់ក្រោមជាតិ) និងបញ្ហាដែលកើតមានឡើងនៅក្នុងប្រតិបត្តិការធនធានរ៉ែ។

គ- រៀបចំក្រុមប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធក្នុងទិសដៅធ្វើឱ្យមានសង្គតិភាពរវាងផែនការអភិវឌ្ឍវិស័យរ៉ែនិងផែនការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនានាមានផ្លូវថ្នល់ ផ្លូវដែក អគ្គិសនី ទឹកស្អាត។ល។

ឃ- រៀបចំអភិក្រមតួនាទីដែលមិនមែនជាបញ្ញត្តិកម្ម ដើម្បីឱ្យក្លាយជាមធ្យោបាយដ៏មានប្រសិទ្ធភាពមួយទៀត ក្នុងការជួយធ្វើឱ្យសម្រេចបាននូវការអភិវឌ្ឍប្រកបដោយចីរភាពនិងការទទួលខុសត្រូវ។ តួនាទីនេះមានសារៈសំខាន់ក្នុងការបំពេញបន្ថែមទៅលើបញ្ញត្តិកម្មដែលមិនទាន់ពេញលេញឬចន្លោះប្រហោង ដូចជាក្រមប្រតិបត្តិ (Codes of Practice) គោលការណ៍ណែនាំ (Guidelines) និងគំនិតផ្តួចផ្តើមស្ម័គ្រចិត្ត (Voluntary Initiatives) ដទៃទៀតដែលមិនមានចែងក្នុងបញ្ញត្តិកម្ម។

ង- ផ្តោតការយកចិត្តទុកដាក់លើសារៈសំខាន់នៃវិទ្យាសាស្ត្ររ៉ែ ដោយជំរុញឬតម្រូវឱ្យប្រើប្រាស់បច្ចេកវិទ្យាជឿនលឿនក្នុងការធ្វើអាជីវកម្មធនធានរ៉ែ។ ការវាយតម្លៃកំណត់បានយ៉ាងសុក្រឹត (Accurate Delineation) អំពីជម្រករ៉ែ អាស្រ័យដោយការប្រើប្រាស់វិធីសាស្ត្រស្វែងរុករកទំនើបនិងមានលក្ខណៈវិទ្យាសាស្ត្រ ហើយដើម្បីឱ្យការទាញយករ៉ែរក្សាបាននូវសុវត្ថិភាពនិងបរិស្ថានល្អប្រសើរ ក៏ទាមទារឱ្យមាននូវការប្រើប្រាស់វិស្វកម្មជឿនលឿន រួមនឹងឧបករណ៍សម្ភារៈ ព្រមទាំងបច្ចេកវិទ្យាទំនើបៗផងដែរ។

ច- ផ្តល់ការគាំទ្រលើទស្សនាទាននៃការការពារការបំពុលបរិស្ថាន ដោយឈរលើគោលការណ៍ការពារបរិស្ថានក្នុងប្រតិបត្តិការធនធានរ៉ែ ដែលគិតគូរចាប់តាំងពីដំណាក់កាលសិក្សាស្រាវជ្រាវការទាញយករ៉ែ ប្រព្រឹត្តិកម្មរ៉ែ ការប្រើប្រាស់ឧបករណ៍ គ្រឿងចក្រ ថាមពល ប្រព័ន្ធគ្រប់គ្រងសំណល់រ៉ែ (Tailing System) ការទុកដាក់សំណល់ និងការបិទការដ្ឋានរ៉ែ។

### ២- ការគ្រប់គ្រងបរិស្ថាន

ការប្រតិបត្តិក្នុងការគ្រប់គ្រងបរិស្ថានដ៏ល្អឆ្លុះបញ្ចាំងពីការទទួលខុសត្រូវក្នុងការអភិវឌ្ឍធនធានរ៉ែដែលជាភារកិច្ចរបស់អ្នកពាក់ព័ន្ធទាំងអស់។ ការគ្រប់គ្រងបរិស្ថានមិនបានល្អនឹងធ្វើឱ្យមានផលប៉ះពាល់ដល់ប្រព័ន្ធអេកូឡូស៊ី (Ecosystems) ដែលរួមមាន សត្វ រុក្ខជាតិ ស្រទាប់ដី ទឹក និងខ្យល់អាកាស ដែលផលប៉ះពាល់បរិស្ថាននេះនឹងបន្ថែមបន្ទុកទៅលើការចំណាយបរិស្ថានកាន់តែខ្ពស់ ដែលជាហេតុធ្វើឱ្យចំណូលរដ្ឋកាន់តែចុះទាប។ ក្នុងករណីធ្ងន់ធ្ងរ ផលប៉ះពាល់បរិស្ថាននេះនឹងបង្ខំឱ្យធ្វើការបិទការដ្ឋានអាជីវកម្មធនធានរ៉ែដែលបង្កផលប៉ះពាល់និងតំបន់ប៉ះពាល់នោះក្នុងរយៈពេលមួយវែង ដើម្បីធ្វើការជួសជុលបរិស្ថានដែលខូចខាតឡើងវិញ។

ជាទូទៅផលប៉ះពាល់បរិស្ថានក្នុងអាជីវកម្មធនធានរ៉ែមានទៅតាមកម្រិតនៃសកម្មភាពអាជីវកម្ម។ ប្រការនេះទាមទារឱ្យមានការយកចិត្តទុកដាក់ខ្ពស់ក្នុងការតម្រូវឱ្យក្រុមហ៊ុនរ៉ែដាក់នូវផែនការអនុវត្តជាក់លាក់មួយក្នុងការការពារបរិស្ថានទៅតាមដំណាក់កាលនៃការអភិវឌ្ឍ ដែលរួមមានផែនការអនុវត្តក្នុងសកម្មភាពបីជាសំខាន់គឺ (ក) សកម្មភាពក្នុងការស្វែងរុករករ៉ែ (ខ) សកម្មភាពក្នុងការទាញយករ៉ែ និង (គ) សកម្មភាពក្នុងការធ្វើនីតិសម្បទាអណ្តូងរ៉ែដែលបានបិទ។

ការគ្រប់គ្រងបរិស្ថានបានត្រឹមត្រូវនិងមានផែនការច្បាស់លាស់នឹងជៀសវាងបាននូវផលប៉ះពាល់ដែលអាចកើតមាន ឬកាត់បន្ថយបានជាអតិបរមា ឬជួសជុល (Remedy) បានទាន់ពេលវេលានូវការប៉ះពាល់បរិស្ថាននោះដែលនឹងជួយដល់ការអភិវឌ្ឍធនធានរ៉ែឱ្យដំណើរការប្រកបដោយចីរភាព។

**ផែនការសកម្មភាព** :

ក- កំណត់ស្តង់ដាគោលការពារបរិស្ថានសម្រាប់ក្រុមហ៊ុនរ៉ែអនុវត្តទៅតាមដំណាក់កាលនៃផែនការអភិវឌ្ឍ។

ខ- កំណត់ស្តង់ដានៃការគ្រប់គ្រងនិងប្រើប្រាស់ទឹក ទឹកលើដីនិងទឹកក្រោមដី។

គ- កំណត់ស្តង់ដានៃការគ្រប់គ្រងនិងការបញ្ចេញចោលសំណល់រាវ ក្នុងនោះត្រូវយកចិត្តទុកដាក់ចំពោះការប្រើប្រាស់ទឹកសំណល់ឡើងវិញ។

ឃ- កំណត់ស្តង់ដានៃការគ្រប់គ្រងសំណល់រ៉ែ ដើម្បីធានាថារចនាសម្ព័ន្ធទាំងអស់មានដូចជាកន្លែងទុកដាក់សំណល់ (Waste Dumps) និងប្រព័ន្ធគ្រប់គ្រងសំណល់រ៉ែ (Tailing System) ត្រូវបានរៀបចំនិងដំណើរការត្រឹមត្រូវតាមបច្ចេកទេសក្នុងប្រតិបត្តិការធនធានរ៉ែ និងបន្ទាប់ពីពេលដែលអណ្តូងរ៉ែត្រូវបានបិទ។

ង- អនុវត្តផែនការនីតិសម្បទាអណ្តូងរ៉ែដែលបានបិទ ដោយធានាថាផែនការដែលបានរៀបចំជាមុននោះ ធ្វើបានត្រឹមត្រូវតាមកម្រិតស្តង់ដានិងត្រូវបានធ្វើបច្ចុប្បន្នកម្ម កែតម្រូវជាទៀងទាត់។ ចំពោះអណ្តូងរ៉ែដែលការទាញយករ៉ែមានរយៈពេលខ្លី ការវាយតម្លៃឡើងវិញ ផែនការនីតិសម្បទាអណ្តូងរ៉ែត្រូវធ្វើឱ្យបានញឹកញាប់ជាងអណ្តូងរ៉ែដែលការទាញយករ៉ែមានរយៈពេលវែង។ ទន្ទឹមនោះត្រូវបង្កើតយន្តការធានាហិរញ្ញវត្ថុសម្រាប់ការបិទការដ្ឋានអណ្តូងរ៉ែ ដែលត្រូវតែមានគ្រប់គ្រាន់ក្នុងការចំណាយសម្រាប់ដំណើរការបិទអណ្តូងរ៉ែនិងក្នុងការធ្វើនីតិសម្បទាអណ្តូងរ៉ែ ដែលបញ្ហានេះត្រូវរៀបចំតាំងពីដំណាក់កាលដំបូងនៃអាជីវកម្មធនធានរ៉ែ។

## ៣- ការធានានូវសុវត្ថិភាពអណ្តូងរ៉ែ

ប្រតិបត្តិការធនធានរ៉ែគឺជាប្រភេទនៃសកម្មភាពអាជីវកម្មដែលប្រឈមនឹងគ្រោះថ្នាក់ខ្ពស់។ ជារឿយៗគ្រោះថ្នាក់បានកើតឡើង ហើយលទ្ធផលបានបណ្តាលឱ្យមានការស្លាប់ឬរបួស ពិការដល់អ្នកដែលធ្វើការងារក្នុងសកម្មភាពនោះ។ ដូច្នេះកិច្ចប្រឹងប្រែងបង្កើននូវសុវត្ថិភាពការងារនឹងអាចជួយកាត់បន្ថយឱ្យបានជាអតិបរមានូវគ្រោះថ្នាក់ដែលអាចកើតមានជាយថាហេតុក្នុងប្រតិបត្តិការធនធានរ៉ែ ដែលបញ្ហានេះគឺជាកាតព្វកិច្ចនិងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធគ្រប់ៗរូប។ ការគិតគូរដល់សុខភាពរបស់អ្នកដែលធ្វើសកម្មភាពក្នុងប្រតិបត្តិការធនធានរ៉ែនិងប្រជាពលរដ្ឋដែលរស់នៅជិតខាងតំបន់ការដ្ឋានរ៉ែ ក៏ជាប្រការដែលត្រូវយកចិត្តទុកដាក់ខ្ពស់ផងដែរ។

ត្រូវរៀបចំគោលការណ៍សុវត្ថិភាពនិងសុខភាពអណ្តូងរ៉ែដោយឡែកៗទៅតាមប្រភេទនៃអាជីវកម្មធនធានរ៉ែដើម្បីទប់ស្កាត់ហានិភ័យក្នុងប្រតិបត្តិការធនធានរ៉ែ ដោយផ្អែកលើបទប្បញ្ញត្តិស្តីពីសុវត្ថិភាពនិងសុខភាពអណ្តូងរ៉ែដែលនឹងចែងក្នុងក្រមស្តីពីធនធានរ៉ែ។ ផ្អែកលើគោលការណ៍សុវត្ថិភាពនិងសុខភាពអណ្តូងរ៉ែនេះ ក្រុមហ៊ុនរ៉ែត្រូវដាក់ចេញនូវវិធានផ្ទៃក្នុងស្តីពីសុវត្ថិភាពនិងសុខភាពអណ្តូងរ៉ែជាក់ស្តែងនៅក្នុងគ្រប់សកម្មភាពប្រតិបត្តិការធនធានរ៉ែរបស់ខ្លួន។ ត្រូវធានាថាគ្មានក្រុមហ៊ុនរ៉ែណាមួយអាចធ្វើប្រតិបត្តិការធនធានរ៉ែដោយគ្មានគោលការណ៍សុវត្ថិភាពនិងសុខភាពអណ្តូងរ៉ែឡើយ។

មន្ត្រីអធិការកិច្ចធនធានរ៉ែត្រូវពិនិត្យតាមដានការអនុវត្តច្បាប់ និងគោលការណ៍សុវត្ថិភាពនិងសុខភាពអណ្តូងរ៉ែជាទៀងទាត់និងតាមការចាំបាច់។ ត្រូវបង្កើតនូវលក្ខណវិនិច្ឆ័យដើម្បីវាយតម្លៃលើកសរសើរដល់ប្រតិបត្តិករឬក្រុមហ៊ុនរ៉ែណាដែលប្រតិបត្តិនូវគោលការណ៍សុវត្ថិភាពនិងសុខភាពបានល្អប្រសើរ។ ទន្ទឹមនោះក៏ត្រូវមានវិធានការអប់រំ ពិន័យ ឬដាក់ទោសទណ្ឌផ្សេងៗស្របតាមច្បាប់ចំពោះប្រតិបត្តិករឬក្រុមហ៊ុនរ៉ែ ដែលមិនយកចិត្តទុកដាក់ឬធ្វេសប្រហែសក្នុងការអនុវត្តតាមគោលការណ៍សុវត្ថិភាពនិងសុខភាពអណ្តូងរ៉ែ។

**ផែនការសកម្មភាព** :

ក- ពង្រឹងសមត្ថភាពរបស់មន្ត្រីអធិការកិច្ចធនធានរ៉ែក្នុងការអនុវត្តបទប្បញ្ញត្តិស្តីពីសុវត្ថិភាពនិងសុខភាពអណ្តូងរ៉ែ ដែលទាមទារនូវការបណ្តុះបណ្តាលរយៈពេលខ្លីនិងមធ្យម។ ជាពិសេសត្រូវយកចិត្តទុកដាក់បំពាក់បំប៉នជំនាញជាមូលដ្ឋាន ទន្ទឹមនឹងការបណ្តុះបណ្តាលផ្ទាល់នៅនឹងកន្លែងចំពោះមន្ត្រីថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធ ដើម្បីឱ្យការត្រួតពិនិត្យមានភាពងាយស្រួលនិងឆ្លើយតបទៅនឹងសភាពការណ៍ដែលកើតឡើងជាយថាហេតុបានទាន់ពេលវេលា។

ខ- រៀបចំគោលការណ៍សុវត្ថិភាពនិងសុខភាពអណ្តូងរ៉ែទៅតាមប្រភេទនៃអាជីវកម្មធនធានរ៉ែដូចជាប្រភេទអណ្តូងរ៉ែបើក មានការដ្ឋានវាយថ្ម ការដ្ឋានថ្មអារ ការដ្ឋានធ្យូងថ្ម ប្រភេទអណ្តូងរ៉ែក្រោមដី មានអណ្តូងរ៉ែលោហៈ អណ្តូងរ៉ែអលោហៈ។ល។

គ- តម្រូវឱ្យក្រុមហ៊ុនរ៉ែបង្កើតគោលការណ៍សុវត្ថិភាពនិងសុខភាពអណ្តូងរ៉ែជាក់ស្តែងតាមប្រភេទនៃប្រតិបត្តិការធនធានរ៉ែនិងស្ថានភាពនៃទីតាំងការដ្ឋានរបស់ខ្លួន។

ឃ- តម្រូវឱ្យក្រុមហ៊ុនរ៉ែបង្កើតប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពនិងសុខភាពអណ្តូងរ៉ែ ដែលរួមបញ្ចូលនូវការគ្រប់គ្រងហានិភ័យនិងការប្រតិបត្តិ ដែលធានានូវសុវត្ថិភាពនិងសុខភាពអណ្តូងរ៉ែរបស់មនុស្សដែលអាចរងផលប៉ះពាល់ពីប្រតិបត្តិការធនធានរ៉ែ។ ប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពនិងសុខភាពអណ្តូងរ៉ែត្រូវរៀបចំជាប្រព័ន្ធឯកសារដែលអាចធ្វើសវនកម្មបាន និងជាផ្នែកមួយនៃប្រព័ន្ធគ្រប់គ្រងដោយរួមមានរចនាសម្ព័ន្ធចាត់តាំង ផែនការសកម្មភាព ការទទួលខុសត្រូវការប្រតិបត្តិ នីតិវិធីដំណើរការ និងធនធានសម្រាប់ការអភិវឌ្ឍសមត្ថភាព ការអនុវត្ត និងការត្រួតពិនិត្យឡើងវិញ។

**៤- ការទាញយកធនធានរ៉ែឱ្យអស់លទ្ធភាព**

ក្នុងគោលបំណងឱ្យការទាញយកធនធានរ៉ែប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ការធ្វើអាជីវកម្មធនធានរ៉ែ ត្រូវផ្តោតការយកចិត្តទុកដាក់ខ្ពស់ទៅលើការទាញយកធនធានរ៉ែឱ្យអស់លទ្ធភាពដែលអាចទាញយកបាន ដើម្បីធានាមិនឱ្យមានការខ្ជះខ្ជាយដែលនាំឱ្យបាត់បង់នូវសម្បត្តិធម្មជាតិនិងធានាបាននូវការបង្កើនចំណូលជាតិ។

ធនធានរ៉ែលោហៈតែងតែមានវត្តមានសារធាតុរ៉ែបន្ទាប់បន្សំ(Associated Mineral) ក្នុងបរិមាណតិចតួចនៅលាយឡំជាមួយនឹងសារធាតុរ៉ែចម្បង។ ដូចនេះគ្រប់ការធ្វើអាជីវកម្មធនធានរ៉ែ ក្រុមហ៊ុនត្រូវធ្វើការ

ពិសោធវិភាគឱ្យបានច្បាស់លាស់នូវអត្រារ៉ែបន្ទាប់បន្សំទាំងនោះ ហើយត្រូវធ្វើប្រព្រឹត្តិកម្មចម្រាញ់យកប្រភេទរ៉ែបន្ទាប់បន្សំទាំងនោះស្របតាមការកំណត់ក្នុងស្តង់ដាអត្រារ៉ែបន្ទាប់បន្សំអប្បបរមា។

កម្រិតកាត់ចេញ (Cut-Off Grade) គឺជាកម្រិតអត្រាផ្ទុកលោហធាតុក្នុងរ៉ែអប្បបរមាដែលត្រូវបានកំណត់សម្រាប់តួរ៉ែមួយដើម្បីឱ្យអាជីវកម្មរ៉ែមានផលចំណេញ(Economy viable)។ ពិតមែនតែការវាយតម្លៃដំបូងនៃកម្រិតកាត់ចេញត្រូវបានធ្វើនៅក្នុងដំណាក់កាលសិក្សាសមិទ្ធិលទ្ធភាពក៏ដោយ ក៏ករណីនេះអាស្រ័យជាសំខាន់ទៅលើការយល់ដឹងអំពីសន្និធិរ៉ែដែលមានឬបម្រែបម្រួលនៃលក្ខខណ្ឌទីផ្សារ។ ហេតុនេះមុននឹងធ្វើការសម្រេចលើកម្រិតកាត់ចេញ ស្ថាប័នទទួលបន្ទុកវិស័យរ៉ែត្រូវធ្វើការវាយតម្លៃឱ្យបានត្រឹមត្រូវនូវការប៉ាន់ស្មានធនធានរ៉ែដែលមាន (Mineral Resource Estimate) ប្រៀបធៀបនឹងការចំណាយក្នុងការទាញយកធនធានរ៉ែនោះ។ ការសិក្សាពីថ្លៃផលិតផលរ៉ែ(Commodity Price) តាមទីផ្សារអន្តរជាតិឬការសិក្សាព្យាករថ្លៃផលិតផលរ៉ែក៏ជាកត្តាចាំបាច់ក្នុងការសម្រេចលើកម្រិតកាត់ចេញដែរ។

ត្រូវជំរុញឱ្យមានការប្រើប្រាស់បច្ចេកវិទ្យាទំនើបក្នុងការធ្វើអាជីវកម្មធនធានរ៉ែដែលប្រការនេះមិនត្រឹមតែអាចឱ្យយើងទាញយកធនធានរ៉ែឱ្យបានជាអតិបរមានោះទេថែមទាំងអាចកាត់បន្ថយនូវផលប៉ះពាល់បរិស្ថានបានយ៉ាងប្រសើរ។

**ផែនការសកម្មភាព** :

ក- កំណត់ស្តង់ដាអត្រារ៉ែបន្ទាប់បន្សំអប្បបរមាដែលត្រូវធ្វើប្រព្រឹត្តិកម្មចម្រាញ់យកនិងតម្រូវឱ្យមានការវាយតម្លៃសន្ទស្សន៍ធនធានរ៉ែបន្ទាប់បន្សំដែលមាននៅក្នុងរ៉ែចម្បងក្នុងការធ្វើអាជីវកម្មធនធានរ៉ែ។

ខ- កំណត់កម្រិតកាត់ចេញដោយផ្អែកលើការវាយតម្លៃសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ។

គ- ជំរុញការប្រើប្រាស់បច្ចេកវិទ្យាទំនើបនិងលើកទឹកចិត្តចំពោះការប្រើប្រាស់វិធីសាស្ត្រនៃការធ្វើអាជីវកម្មធនធានរ៉ែមានលក្ខណៈវិទ្យាសាស្ត្រ។

## ៥- ការអភិវឌ្ឍធនធានរ៉ែនិងតំបន់ការពារធម្មជាតិ

គោលបំណងជាចម្បងរបស់រាជរដ្ឋាភិបាលគឺដើម្បីកំណត់ឱ្យបាននូវអត្តសញ្ញាណ ទីតាំង និងទិន្នន័យនៃសក្តានុពលធនធានរ៉ែ ដែលជាសម្បត្តិធម្មជាតិរបស់ជាតិនៅទូទាំងប្រទេសកម្ពុជា ដែលរួមទាំងតំបន់ការពារធម្មជាតិផងដែរ។ ការយល់ដឹងពីសក្តានុពលធនធានរ៉ែជាមុននៅក្នុងតំបន់ការពារធម្មជាតិនឹងជួយដល់រាជរដ្ឋាភិបាលក្នុងការធ្វើសេចក្តីសម្រេចប្រកបដោយសុភវិនិច្ឆ័យថាតើត្រូវអភិរក្សតំបន់ការពារធម្មជាតិ ឬត្រូវធ្វើការអភិវឌ្ឍធនធានរ៉ែទាំងនោះ ដោយឈរលើគោលការណ៍អភិវឌ្ឍប្រកបដោយការទទួលខុសត្រូវខ្ពស់ ក្នុងការអភិរក្សតំបន់ការពារធម្មជាតិ។

ជាទូទៅ ការធ្វើបុរេសនានិងការស្វែងរុករកធនធានរ៉ែមិនមានផលប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថានឡើយ។ ទោះជាយ៉ាងណាក៏ដោយ ការធ្វើសកម្មភាពទាំងនេះនៅក្នុងតំបន់ការពារធម្មជាតិត្រូវតែមាននីតិវិធីពិសេសដោយឡែកពីការស្វែងរុករកធនធានរ៉ែនៅក្នុងតំបន់ដទៃផ្សេងទៀត។ ការធ្វើបុរេសនានិងការស្វែងរុករកធនធានរ៉ែនេះអាចអនុវត្តដោយក្រសួងទទួលបន្ទុកវិស័យរ៉ែ ផ្នែកឯកជន ឬដោយសហប្រតិបត្តិការជាមួយនឹងដៃគូអន្តរជាតិនិងចាំបាច់ត្រូវមានការចូលរួមពីក្រសួងនិងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលពាក់ព័ន្ធនឹងតំបន់ការពារធម្មជាតិនោះ។

ក្រោយពីកំណត់បាននូវធនធានរ៉ែដែលមានសក្តានុពលខ្ពស់នៅក្នុងតំបន់ការពារធម្មជាតិរួចហើយ ត្រូវធ្វើការវាយតម្លៃប្រសិទ្ធភាពសេដ្ឋកិច្ចនៃផលដែលនឹងទទួលបានពីអាជីវកម្មធនធានរ៉ែនោះមកវិញ ហើយជំហានបន្ទាប់គឺធ្វើការពិគ្រោះយោបល់ជាមួយនឹងក្រសួងស្ថាប័នពាក់ព័ន្ធ មុននឹងដាក់ជូនរាជរដ្ឋាភិបាលសម្រេច។ ក្នុងនោះត្រូវកំណត់ឱ្យបានច្បាស់អំពីបញ្ហាមួយចំនួនមាន នីតិវិធីក្នុងការអនុញ្ញាតឱ្យធ្វើអាជីវកម្ម លក្ខខណ្ឌចាំបាច់ក្នុងការការពារបរិស្ថាន ការពារព្រៃឈើនិងជីវៈចម្រុះ និងពីលក្ខខណ្ឌពិសេសសម្រាប់ការបង្កើតរោងចក្រប្រព្រឹត្តិកម្មរ៉ែនៅក្នុងតំបន់ការពារធម្មជាតិក្នុងករណីចាំបាច់។

ក្នុងទិសដៅការពារបរិស្ថាននិងកាត់បន្ថយឱ្យបានជាអតិបរមានូវផលប៉ះពាល់អវិជ្ជមានលើបរិស្ថាន ចាំបាច់ត្រូវរៀបចំយន្តការត្រួតពិនិត្យពិសេសមួយ ដើម្បីអនុវត្តនូវវិធានការត្រួតពិនិត្យយ៉ាងតឹងរ៉ឹងដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិនានាជាធរមាននិងតាមឧត្តមានុវត្តជាអន្តរជាតិ។

**ផែនការសកម្មភាព :**

ក- បង្កើតនីតិវិធីដោយឡែកសម្រាប់ការធ្វើបុរេសនានិងការស្វែងរុករកធនធានរ៉ែនៅក្នុងតំបន់ការពារធម្មជាតិ ដោយយកចិត្តទុកដាក់អំពីផលប៉ះពាល់បរិស្ថាន ព្រៃឈើ ប្រព័ន្ធអេកូឡូស៊ី ជីវៈចម្រុះ សត្វ និងរុក្ខជាតិ។

ខ- បង្កើតនីតិវិធីដោយឡែកក្នុងការអនុញ្ញាតឱ្យធ្វើអាជីវកម្មធនធានរ៉ែ នៅក្នុងតំបន់ការពារធម្មជាតិ និងសិក្សាកំណត់លក្ខខណ្ឌចាំបាច់នានាក្នុងការការពារបរិស្ថាន ប្រព័ន្ធអេកូឡូស៊ី ជីវៈចម្រុះ សត្វ និងរុក្ខជាតិ។ ការប្រើឧបករណ៍ដែលមានបច្ចេកវិទ្យាខ្ពស់ ដែលកាត់បន្ថយផលប៉ះពាល់បរិស្ថានជាអតិបរមាក្នុងការទាញយករ៉ែគឺជាប្រការតម្រូវចាំបាច់ក្នុងការធ្វើអាជីវកម្ម។

គ- បង្កើតលក្ខខណ្ឌដោយឡែកសម្រាប់ការបង្កើតរោងចក្រប្រព្រឹត្តិកម្មរ៉ែ នៅក្នុងតំបន់ការពារធម្មជាតិ។

ឃ- បង្កើតយន្តការត្រួតពិនិត្យតាមកាលកំណត់ និងដោយមិនបាច់ជូនដំណឹងជាមុន ដោយអនុវត្តនូវវិធានការដែលមានប្រសិទ្ធភាព (Effective Measure) ដើម្បីពិនិត្យវាយតម្លៃការប្រតិបត្តិរបស់ក្រុមហ៊ុនរ៉ែនិងចាត់វិធានការឆ្លើយតបឱ្យបានទាន់ពេលវេលា។

## គោលដៅទី៣- អភិវឌ្ឍធនធានរ៉ែនិងសហគមន៍

### ១- ការអភិវឌ្ឍសហគមន៍

ការបង្កើតចំណូលឱ្យបានជាអតិបរមាពីវិស័យរ៉ែគឺជាការចង់បានរបស់រាជរដ្ឋាភិបាល ដើម្បីយកចំណូលនោះមកបម្រើដល់វិស័យសេដ្ឋកិច្ចនិងសង្គមផ្សេងៗទៀត។ ប៉ុន្តែក្រៅពីចំណូលផ្ទាល់ដែលរដ្ឋទទួលបាន រាជរដ្ឋាភិបាលក៏ផ្តោតការយកចិត្តទុកដាក់ដល់ការអភិវឌ្ឍសហគមន៍នៅក្នុងតំបន់ដែលធនធានរ៉ែកំពុងត្រូវបានធ្វើអាជីវកម្ម និងនៅក្នុងតំបន់ក្បែរខាងតំបន់ធនធានរ៉ែទាំងនោះផងដែរ ព្រោះថាប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ធនធានរ៉ែទាំងនោះត្រូវតែជាអ្នកដែលទទួលផលមុនគេពីសម្បត្តិធម្មជាតិរបស់ជាតិ។

ការអភិវឌ្ឍសហគមន៍បានល្អដោយមានផែនការច្បាស់លាស់នឹងជួយឱ្យការអភិវឌ្ឍធនធានរ៉ែដំណើរការទៅបានប្រកបដោយចីរភាពនិងមានការចូលរួមគាំទ្រពីប្រជាពលរដ្ឋដែលរស់នៅក្នុងសហគមន៍ទាំងឡាយនោះ។ ប្រការនេះទាមទារឱ្យមានការបញ្ជ្រាបការយល់ដឹងជាសាធារណៈដល់ប្រជាពលរដ្ឋក្នុងតំបន់សម្បទានធនធានរ៉ែឱ្យយល់អំពីដំណើរការអភិវឌ្ឍធនធានរ៉ែ អំពីផលប្រយោជន៍ដែលរដ្ឋនិងសហគមន៍ទទួលបាន អំពីផលប៉ះពាល់នានា និងអំពីការការពារនិងបញ្ចៀសផលប៉ះពាល់ទាំងនោះ។

ការចូលរួមយោបល់ពីសហគមន៍និងការទទួលយកនូវសំណូមពរសមហេតុផលពីសហគមន៍និងជួយដល់អ្នកពាក់ព័ន្ធទាំងអស់មានរដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ និងជាពិសេសគឺក្រុមហ៊ុនរ៉ែឱ្យកាត់បន្ថយបាននូវហានិភ័យនានាក្នុងអាជីវកម្មធនធានរ៉ែដែលបណ្តាលមកពីកង្វះការគាំទ្រពីប្រជាពលរដ្ឋក្នុងសហគមន៍និងបង្កើតបាននូវភាពសុខដុមរវាងអ្នកពាក់ព័ន្ធនិងសហគមន៍។

**ផែនការសកម្មភាព :**

ក- កំណត់ការរៀបចំផែនការការទទួលខុសត្រូវសង្គមរួម(Corporate Social Responsibility) ជាផ្នែកមួយនៃការសិក្សាសមិទ្ធិលទ្ធភាព ដែលក្រុមហ៊ុនឧស្សាហកម្មអាជីវកម្មធនធានរ៉ែត្រូវដាក់ជូនរាជរដ្ឋាភិបាលក្នុងពេលស្នើសុំអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ។ ផែនការនេះត្រូវរួមបញ្ចូលនូវការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់ធនធានរ៉ែនិងដោយឡែកចំពោះតំបន់ដាច់ស្រយាលត្រូវបញ្ចូលនូវផែនការផ្តល់សេវាអប់រំ ផ្តល់ទឹកស្អាត និងការការពារសុខភាពបឋមដល់ប្រជាពលរដ្ឋក្នុងសហគមន៍ធនធានរ៉ែ។

ខ- ជំរុញឱ្យក្រុមហ៊ុនឧស្សាហកម្មអាជីវកម្មធនធានរ៉ែបង្កើតមូលនិធិអភិវឌ្ឍសង្គមនៅក្នុងតំបន់អាជីវកម្មធនធានរ៉ែ។ ការគ្រប់គ្រងនិងការប្រើប្រាស់មូលនិធិនេះ ត្រូវកំណត់ក្នុងលក្ខន្តិកៈដែលមានការឯកភាពរវាងក្រុមហ៊ុននិងសហគមន៍។ ប្រភពហិរញ្ញវត្ថុរបស់មូលនិធិបានមកពីចំណែកនៃប្រាក់ចំណេញរបស់ក្រុមហ៊ុននិងពីការបែងចែកកម្រៃសួយសារពីរាជរដ្ឋាភិបាលក្នុងអត្រាកំណត់មួយ។ គួរកំណត់ផងដែរអំពីគោលការណ៍និងមធ្យោបាយដោះស្រាយទំនាស់ក្នុងករណីដែលកើតមាន។

គ- បង្កើតមូលនិធិរ៉ែទ្រទ្រង់កិច្ចអភិវឌ្ឍសហគមន៍មូលដ្ឋាន ដែលក្រុមហ៊ុនរ៉ែត្រូវរួមចំណែកបង់ចូលមូលនិធិនេះ តាមអត្រាកំណត់មួយសមាមាត្រទៅនឹងបរិមាណនៃផលិតកម្មរ៉ែ។ មូលនិធិនេះនឹងត្រូវប្រើប្រាស់ជាប្រយោជន៍ដល់សហគមន៍មូលដ្ឋានដែលការដ្ឋានរ៉ែស្ថិតនៅ ឬរងផលប៉ះពាល់ដោយផ្ទាល់ឬដោយប្រយោល។

ឃ- បញ្ជ្រាបការយល់ដឹងជាសាធារណៈដល់ប្រជាពលរដ្ឋក្នុងតំបន់ ដែលមានគម្រោងអភិវឌ្ឍធនធានរ៉ែតាមរយៈការអប់រំពន្យល់អំពីគម្រោងអភិវឌ្ឍនោះ។ ផែនការបញ្ជ្រាបការយល់ដឹងនេះត្រូវធ្វើដោយមានការចូលរួមពីរដ្ឋបាលថ្នាក់ក្រោមជាតិនិងតំណាងប្រជាពលរដ្ឋក្នុងសហគមន៍។

ង- បង្កើតយន្តការអភិវឌ្ឍសហគមន៍ដែលជាយន្តការគន្លឹះសម្រាប់សមធម៌សង្គមក្នុងការបែងចែកភាគផលដែលបានមកពីចំណូលពីវិស័យរ៉ែដល់សហគមន៍រ៉ែនិងផ្តល់ឱកាសដល់ប្រជាពលរដ្ឋ

ក្នុងតំបន់សហគមន៍រ៉ែចូលរួមធ្វើការសម្រេចចិត្តក្នុងការអភិវឌ្ឍសហគមន៍មូលដ្ឋានរបស់ខ្លួនដោយផ្ទាល់។ នេះជាយន្តការចំហដែលអាចឱ្យមានការចូលរួមពីសមាគមឬអង្គការសង្គមស៊ីវិលផ្សេងៗដែលមានសមត្ថភាពគ្រប់គ្រាន់ក្នុងការសម្របសម្រួលនិងគាំទ្រដើម្បីឱ្យគម្រោងអភិវឌ្ឍសហគមន៍ទទួលបានជោគជ័យ។

### ២- ការប្រើពលកម្មក្នុងតំបន់និងការងារយេនឌ័រ

ប្រតិបត្តិការធនធានរ៉ែចាប់ផ្ដើមពីការធ្វើបុរេសនា ការស្វែងរុករក និងការជីកយករ៉ែ ការសាងសង់ និងដំណើរការប្រព្រឹត្តកម្មរ៉ែ សុទ្ធតែបង្កើតនូវតម្រូវការពលកម្ម ទំនិញ និងសេវាកម្មផ្សេងៗទៀត។ ការជំរុញឱ្យក្រុមហ៊ុនរ៉ែប្រើកម្លាំងពលកម្មដែលមានក្នុងតំបន់ឱ្យបានច្រើនគឺជាបញ្ហាអាទិភាពដែលក្រុមហ៊ុនរ៉ែត្រូវផ្ដល់ដល់សហគមន៍ដើម្បីរួមចំណែកលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋក្នុងតំបន់ធនធានរ៉ែ។ ទន្ទឹមនឹងការរៀបចំផែនការបណ្ដុះបណ្ដាលផ្ទាល់នៅនឹងកន្លែងរយៈពេលខ្លីឬមធ្យម ក្រុមហ៊ុនរ៉ែត្រូវគិតគូរបន្ថែមទៀតលើការរៀបចំផែនការបណ្ដុះបណ្ដាលរយៈពេលវែងដល់កូនចៅប្រជាពលរដ្ឋក្នុងសហគមន៍ ដើម្បីឱ្យពួកគេអាចចូលបម្រើការងារក្នុងអាជីវកម្មធនធានរ៉ែបានក្នុងមូលដ្ឋានដែលពួកគេរស់នៅនាថ្ងៃអនាគត។

ការយកចិត្តទុកដាក់ដល់បញ្ហាយេនឌ័រ ក៏ជាប្រធានបទសំខាន់មួយដែលតម្រូវឱ្យក្រុមហ៊ុនរ៉ែត្រូវពិនិត្យពិចារណាដល់ការប្រើកម្លាំងពលកម្មស្ត្រីដោយគ្មានការរើសអើងក្នុងអាជីវកម្មធនធានរ៉ែ។ ជាទូទៅអាជីវកម្មធនធានរ៉ែមានទំនោរក្នុងការប្រើកម្លាំងពលកម្មបុរសច្រើនជាងស្ត្រី ប៉ុន្តែអាស្រ័យដោយការរីកចម្រើនក្នុងការប្រើប្រាស់បច្ចេកវិទ្យាជឿនលឿនក្នុងអាជីវកម្មធនធានរ៉ែ ទន្ទឹមនឹងកម្រិតចំណេះដឹងរបស់ស្ត្រីក្នុងវិស័យគ្រប់គ្រង និងបច្ចេកទេសកាន់តែខ្ពស់នោះ ការប្រើកម្លាំងពលកម្មស្ត្រីក្នុងវិស័យរ៉ែ មិនមែនជាឧបសគ្គសម្រាប់ក្រុមហ៊ុនរ៉ែក្នុងការគិតគូរពិចារណាទៀតនោះទេ។ ជាងនេះទៅទៀត ក្រុមហ៊ុនរ៉ែត្រូវយកចិត្តទុកដាក់ក្នុងការលើកទឹកចិត្តដល់ស្ត្រីឱ្យចូលរួមដោយផ្ទាល់ឬប្រយោលក្នុងអាជីវកម្មធនធានរ៉ែ ដោយផ្ដល់នូវការងារសមស្របនិងផ្ដល់នូវសេវាថែទាំសុខភាពជាពិសេសដល់ស្ត្រី។

**ផែនការសកម្មភាព** :

ក- កំណត់គោលការណ៍ជំរុញឱ្យក្រុមហ៊ុនរ៉ែប្រើពលកម្មនិងសេវាកម្មដែលមានក្នុងតំបន់ដែលក្រុមហ៊ុនរ៉ែធ្វើអាជីវកម្ម។

ខ- ជំរុញឱ្យក្រុមហ៊ុនរ៉ែបង្កើតវគ្គបំពាក់បំប៉នជំនាញនៅក្នុងសហគមន៍។

គ- យកចិត្តទុកដាក់ដល់ការប្រើពលកម្មជាស្ត្រីនៅក្នុងអាជីវកម្មធនធានរ៉ែ នៅទីកន្លែងដែលមិនប្រឈមគ្រោះថ្នាក់ខ្លាំង។ ទន្ទឹមនឹងនោះយកចិត្តទុកដាក់ផ្ដល់នូវសេវាថែទាំសុខភាពជាពិសេសដល់ស្ត្រី។

### ៣- ជនជាតិដើមភាគតិចនិងអាជីវកម្មធនធានរ៉ែ

តំបន់ធនធានរ៉ែមួយចំនួនស្ថិតនៅក្នុងតំបន់ដែលមានជនជាតិដើមភាគតិចរស់នៅ។ ដូច្នេះការធ្វើអាជីវកម្មធនធានរ៉ែនៅក្នុងតំបន់ទាំងនោះត្រូវតែគោរពឱ្យបាននូវសិទ្ធិសេរីភាព ទំនៀមទម្លាប់ប្រពៃណី វប្បធម៌ និងជំនឿ

សាសនាផ្សេងៗគ្នារបស់ជនជាតិដើមភាគតិចដែលរស់នៅក្នុងតំបន់នោះ។ ការរំលោភបំពានប៉ះពាល់ដល់ទីសក្ការៈគោរពបូជារបស់ជនជាតិដើមភាគតិចត្រូវហាមឃាត់។ ក្រុមហ៊ុនរ៉ែត្រូវស្វែងយល់ពីទំនៀមទម្លាប់ ប្រពៃណី វប្បធម៌និងជំនឿសាសនារបស់ជនជាតិដើមភាគតិចនីមួយៗដែលមានក្នុងមូលដ្ឋានអាជីវកម្មរបស់ខ្លួនដើម្បីជៀសវាងឱ្យបាននូវការប៉ះពាល់ដល់សិទ្ធិសេរីភាព ទំនៀមទម្លាប់ប្រពៃណី វប្បធម៌ ជំនឿសាសនា និងអារម្មណ៍ (Spirit) របស់ជនជាតិដើមភាគតិច។

**ផែនការសកម្មភាព** :

ផ្តល់ការការពារដល់ជនជាតិដើមភាគតិចក្នុងតំបន់អភិវឌ្ឍធនធានរ៉ែ ដោយរក្សាឱ្យបាននូវសិទ្ធិសេរីភាព ទំនៀមទម្លាប់ ប្រពៃណី វប្បធម៌ និងជំនឿសាសនារបស់ជនជាតិដើមភាគតិចស្របតាមគោលនយោបាយនិងច្បាប់របស់រដ្ឋ។

## គោលដៅទី៤- អភិវឌ្ឍសិប្បកម្មរ៉ែនិងអាជីវកម្មរ៉ែខ្នាតតូច

### ១- សិប្បកម្មរ៉ែនិងអាជីវកម្មរ៉ែខ្នាតតូច

សិប្បកម្មរ៉ែនិងអាជីវកម្មរ៉ែខ្នាតតូចគឺជាប្រភេទអាជីវកម្មដែលមិនអាចខ្វះបានក្នុងប្រទេសដែលកំពុងអភិវឌ្ឍ។ ពិតមែនតែសិប្បកម្មរ៉ែនិងអាជីវកម្មរ៉ែខ្នាតតូចគឺជាប្រភេទអាជីវកម្មដែលស្ថិតនៅរាយប៉ាយ មានច្រើនប្រភេទនិងធ្វើអាជីវកម្មដោយអ្នកជីកយករ៉ែដែលគ្មានជំនាញក្តី ប៉ុន្តែអាជីវកម្មនេះផ្តល់នូវការរួមចំណែកដល់សេដ្ឋកិច្ចជាតិ ផ្តល់នូវការផ្គត់ផ្គង់វត្ថុធាតុដើមរ៉ែដល់ការប្រើប្រាស់ក្នុងស្រុក ស្រូបយកកម្លាំងពលកម្មក្នុងមូលដ្ឋាន ហើយជាពិសេសការទាញយកមកប្រើប្រាស់នូវធនធានរ៉ែពីក្នុងជម្រករ៉ែតូចៗដែលគ្មានសក្តានុពលសេដ្ឋកិច្ច មិនអាចឱ្យក្រុមហ៊ុនរ៉ែធំៗធ្វើអាជីវកម្មទទួលនូវផលចំណេញបាន។

សិប្បកម្មរ៉ែនិងអាជីវកម្មរ៉ែខ្នាតតូចដែលធ្វើប្រតិបត្តិការយករ៉ែដោយគ្មានការអនុញ្ញាត បានបង្កផលប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថាននិងសង្គម ជាពិសេសការធ្វើអាជីវកម្មធនធានរ៉ែមាសនិងត្បូង ទាមទារឱ្យមានវិធានការគ្រប់គ្រងច្បាស់លាស់។

ផ្តើមចេញពីសារៈសំខាន់ខាងលើនេះ រាជរដ្ឋាភិបាលនឹងធ្វើការសិក្សាកំណត់នូវអត្តសញ្ញាណជម្រករ៉ែខ្នាតតូច ព្រមទាំងកំណត់នូវគោលការណ៍ជាមូលដ្ឋាននៃសិប្បកម្មរ៉ែនិងអាជីវកម្មរ៉ែខ្នាតតូច។ រាជរដ្ឋាភិបាលយកចិត្តទុកដាក់សម្រួលដល់ការអភិវឌ្ឍសិប្បកម្មរ៉ែនិងអាជីវកម្មរ៉ែខ្នាតតូចឱ្យដំណើរការក្នុងការគ្រប់គ្រងដ៏ល្អដើម្បីធានាឱ្យការធ្វើអាជីវកម្មទាញយករ៉ែពីក្នុងជម្រករ៉ែខ្នាតតូចមានសុវត្ថិភាព ស្ថិរភាព គ្មានផលប៉ះពាល់ដល់បរិស្ថាន និងផ្តល់ផលវិជ្ជមានដល់សេដ្ឋកិច្ចជាតិ។

**ផែនការសកម្មភាព** :

ក- សិក្សាកំណត់អត្តសញ្ញាណជម្រករ៉ែខ្នាតតូចដែលរួមមានប្រភេទនៃរ៉ែ បរិមាណរ៉ែដែលមាន (Reserve) និងទីតាំងនៃជម្រករ៉ែនោះ។

ខ- ផ្តល់ការអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈដល់សិប្បករនិងអាជីវកររ៉ែខ្នាតតូច ឱ្យយល់ដឹងពីច្បាប់ ពីហានិភ័យដែលបណ្តាលមកពីការប្រើប្រាស់សារធាតុគ្រោះថ្នាក់ ពីការបញ្ចៀសនិងការ

គ្រប់គ្រងហានិភ័យ។ ការអប់រំនិងបណ្តុះបណ្តាលក៏ត្រូវផ្តោតទៅលើបញ្ហាសុខភាព សុវត្ថិភាព បរិស្ថាន និងទៅលើលក្ខណៈសេដ្ឋកិច្ចក្នុងអាជីវកម្មផងដែរ។

គ- ផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់អាជីវកម្មរ៉ែខ្នាតតូច ឱ្យមានភាពទូលំទូលាយតាមរយៈការសិក្សាស្រាវជ្រាវនិងអភិវឌ្ឍ (Research and Development) ផ្តល់នូវបច្ចេកវិទ្យាជឿនលឿនសមស្របដល់អាជីវកររ៉ែខ្នាតតូច។

ឃ- សម្រួលនីតិវិធីក្នុងការស្នើសុំច្បាប់អនុញ្ញាត ដោយសម្រួលបែបបទរដ្ឋបាលក្នុងការស្នើសុំ។ ទន្ទឹមនោះនឹងពិនិត្យកំណត់ការធ្វើប្រតិភូកម្មទៅថ្នាក់ក្រោមជាតិ ចំពោះការទាញយករ៉ែដែលគ្មានគ្រោះថ្នាក់និងមានរយៈពេលខ្លី ដូចជាការជីកយកខ្សាច់ យកអាចម៍ដី និងវាយថ្មជាដើម។

ង- លើកទឹកចិត្តក្នុងការចងក្រងសិប្បកម្មរ៉ែនិងអាជីវកម្មរ៉ែខ្នាតតូចជាចង្កោម (Cluster) ឬជាសហគមន៍ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង ការបណ្តុះបណ្តាល ការពិគ្រោះយោបល់ ការខ្ចីឥណទានពីធនាគារ និងការធ្វើពាណិជ្ជកម្មរ៉ែក្នុងគោលការណ៍ធុរកិច្ចដ៏ល្អ (Sound Business Principles)។

ច- សម្រួលក្នុងទំនាក់ទំនងពាណិជ្ជកម្មជាមួយនឹងក្រុមហ៊ុនរ៉ែធំៗ ឬឧស្សាហកម្មក្នុងស្រុកលើគោលការណ៍ស្មើភាពនិងសមធម៌ (Principles of Equity and Fairness)។

**២- វិធានការនិងដំណោះស្រាយចំពោះអាជីវកម្មធនធានរ៉ែដែលគ្មានការអនុញ្ញាត**

អាជីវកម្មធនធានរ៉ែដែលគ្មានការអនុញ្ញាតគឺជាការធ្វើអាជីវកម្មធនធានរ៉ែដោយគ្មានអាជ្ញាបណ្ណពីក្រសួងទទួលបន្ទុកវិស័យរ៉ែ ឬពីអង្គភាពដែលក្រសួងទទួលបន្ទុកវិស័យរ៉ែបានធ្វើប្រតិភូកម្មឱ្យ។ អាជីវកម្មធនធានរ៉ែដែលគ្មានការអនុញ្ញាតផ្តល់នូវផលវិបាកដ៏ធ្ងន់ធ្ងរដល់បរិស្ថាន សង្គម និងសុខភាពមនុស្សឬសត្វដែលរស់នៅជុំវិញទីនោះ ក្នុងរយៈពេលដ៏ខ្លីចំពោះមុខនិងបន្តដល់អនាគតកាលដ៏វែងទៅមុខទៀត ប្រសិនបើគ្មានវិធានការកែលម្អបរិស្ថានឡើងវិញនោះទេ។ អាជីវកម្មធនធានរ៉ែដែលគ្មានការអនុញ្ញាតបានបំផ្លិចបំផ្លាញដល់ជម្រករ៉ែ ព្រោះថាទោះបីជាជម្រករ៉ែនោះធំឬតូចក្តីក៏អាចផ្តល់នូវផលប្រយោជន៍ដល់ជាតិនិងសង្គមដែរ។

អាជីវកម្មធនធានរ៉ែបែបសិប្បកម្មនិងខ្នាតតូចនៅប្រទេសកម្ពុជាបច្ចុប្បន្ន ភាគច្រើនគឺជាអាជីវកម្មធនធានរ៉ែដែលមិនទាន់ទទួលបានការអនុញ្ញាតត្រឹមត្រូវនៅឡើយ។ ការអនុវត្តច្បាប់និងការគ្រប់គ្រងអាជីវកម្មធនធានរ៉ែបែបសិប្បកម្មនិងខ្នាតតូចនៅប្រទេសកម្ពុជាបច្ចុប្បន្ននៅមានកម្រិត ដោយហេតុថារាជរដ្ឋាភិបាលនៅមានភាពអនុគ្រោះនៅឡើយចំពោះអាជីវកម្មប្រភេទនេះ។ ក្រៅពីការធ្វើអាជីវកម្មរ៉ែសំណង់ដែលគ្មានការអនុញ្ញាត ដូចជាការជីកយកខ្សាច់ អាចម៍ដី ក្រួស ថ្មសំណង់ ថ្មសម្អាង។ល។ ដែលកើតមាននៅតាមរាជធានី ខេត្ត ក្រុងមួយចំនួន ការធ្វើអាជីវកម្មរ៉ែមាសនិងត្បូងអនាធិបតេយ្យនៅតាមតំបន់សម្បទានរ៉ែរបស់ក្រុមហ៊ុនរ៉ែ តាមដីសាធារណៈរបស់រដ្ឋនិងដីជាកម្មសិទ្ធិឯកជនតាមបណ្តាខេត្តភាគខាងលិចនិងឦសានប្រទេសកំពុងតែកើតមានជាបន្តបន្ទាប់។

ការធ្វើអាជីវកម្មធនធានរ៉ែដែលគ្មានការអនុញ្ញាតនឹងត្រូវលុបបំបាត់។ រាជរដ្ឋាភិបាលនឹងដាក់ចេញនូវវិធានការទប់ស្កាត់និងវិធានការអប់រំតម្រង់ទិសចំពោះអាជីវកម្មធនធានរ៉ែទាំងនោះឱ្យមានប្រសិទ្ធភាព ដោយធ្វើ

ការសិក្សាពិនិត្យតាមករណីនីមួយៗ។ វិធានការដែលរាជរដ្ឋាភិបាលប្រកាន់យកទាំងឡាយនោះ គឺសំដៅធ្វើឱ្យប្រសើរនូវគុណភាពនៃជីវិតរបស់អ្នកជីកយករ៉ែដែលគ្មានការអនុញ្ញាត និងអ្នកដែលរងផលប៉ះពាល់ដោយផ្ទាល់ឬដោយប្រយោលពីសកម្មភាពគ្មានការអនុញ្ញាតនោះ។ វិធានការនោះក៏សំដៅធ្វើឱ្យប្រសើរដល់ការរួមចំណែកអភិវឌ្ឍប្រកបដោយចីរភាពនិងប្រកបដោយការទទួលខុសត្រូវចំពោះវិស័យរ៉ែកម្ពុជាផងដែរ។

ការទប់ស្កាត់និងការអប់រំតម្រង់ទិសចំពោះអាជីវកម្មធនធានរ៉ែដែលគ្មានការអនុញ្ញាត ទាមទារឱ្យមានការចូលរួមពីសង្គមស៊ីវិលនិងប្រជាពលរដ្ឋ។ ក្នុងន័យនេះ សង្គមស៊ីវិលនិងប្រជាពលរដ្ឋអាចអនុវត្តសិទ្ធិរបស់ខ្លួនស្របតាមច្បាប់ដើម្បីចូលរួមជួយដល់រាជរដ្ឋាភិបាល ក្នុងការលុបបំបាត់អាជីវកម្មធនធានរ៉ែដែលគ្មានការអនុញ្ញាត។

**ផែនការសកម្មភាព** :

ក- ទប់ស្កាត់អាជីវកម្មធនធានរ៉ែដែលគ្មានការអនុញ្ញាត គឺជាវិធានការដំបូងនិងចាំបាច់បំផុតដែលត្រូវប្រកាន់យក។ ការចូលរួមយ៉ាងសកម្មប្រកបដោយស្មារតីទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់ជាន់ថ្នាក់ ក្នុងការទប់ស្កាត់អាជីវកម្មធនធានរ៉ែដែលគ្មានការអនុញ្ញាតគឺជាប្រការដ៏មានប្រសិទ្ធភាពបំផុតក្នុងការរួមចំណែកថែរក្សាធនធានរ៉ែឱ្យស្ថិតនៅគង់វង្សជាប្រយោជន៍របស់រដ្ឋនិងរួមចំណែករក្សាបាននូវបរិស្ថាននិងសង្គម។ គណៈកម្មាធិការទប់ស្កាត់អាជីវកម្មធនធានរ៉ែដែលគ្មានការអនុញ្ញាតរាជធានី ខេត្តនឹងត្រូវបង្កើតឡើងដោយមានការចូលរួមពីស្ថាប័នមន្ទីរពាក់ព័ន្ធ ព្រមទាំងត្រូវដាក់ចេញនូវយន្តការអនុវត្តជាប្រចាំ ដើម្បីកុំឱ្យអាជីវកម្មធនធានរ៉ែដែលគ្មានការអនុញ្ញាតទាំងនេះកើតមានឡើងក្នុងដែនដីសមត្ថកិច្ចរបស់ខ្លួន។

ខ- សិក្សាអំពីទំហំនៃអាជីវកម្មធនធានរ៉ែដែលគ្មានការអនុញ្ញាតដែលកំពុងកើតមាននៅទូទាំងប្រទេស ជាពិសេសរ៉ែមាស ដោយកំណត់ឱ្យបានអំពីទីតាំង ចំនួនអ្នកជីករ៉ែដែលគ្មានការអនុញ្ញាត បែបផែននៃការធ្វើអាជីវកម្ម (ផ្ទាល់ខ្លួនឬបម្រើឱ្យឈ្មួញកណ្តាល) និងផលប៉ះពាល់។

គ- អប់រំអំពីគ្រោះថ្នាក់នៃការប្រើប្រាស់រំសេវជាតិផ្ទុះនិងសារធាតុគីមីមានបារត ស្យានីត ឬសារធាតុគីមីផ្សេងទៀតដែលបង្កគ្រោះថ្នាក់ ឬផលប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពនិងបរិស្ថានជុំវិញ។

ឃ- ពិពិធកម្មមុខរបរចំពោះអ្នកជីករ៉ែដែលគ្មានការអនុញ្ញាតក្នុងទិសដៅឱ្យពួកគេមានមុខរបរចិញ្ចឹមជីវិតផ្សេងក្រៅពីការងារយករ៉ែ ដោយសហការជាមួយនឹងក្រុមហ៊ុនសម្បទានរ៉ែក្នុងការផ្តល់នូវការងារ ការបង្កើតមុខរបរថ្មី ដូចជាការធ្វើកសិកម្ម ចិញ្ចឹមសត្វ កាត់ដេរ។ល។ សម្រាប់បម្រើផ្គត់ផ្គង់ឬផ្តល់សេវាដល់ក្រុមហ៊ុនសម្បទានរ៉ែវិញ។

ង- ចងក្រងជាសហគមន៍និងធ្វើសមាហរណកម្មស្របទៅតាមក្របខណ្ឌច្បាប់ ចំពោះអាជីវកម្មធនធានរ៉ែដែលគ្មានការអនុញ្ញាតនៅតំបន់ដីសាធារណៈរបស់រដ្ឋនិងដីកម្មសិទ្ធិឯកជន នៅពេលសិក្សាឃើញថាតំបន់ទាំងនោះមិនមានសក្តានុពលធនធានរ៉ែសម្រាប់ឧស្សាហកម្មរ៉ែធំៗ។

ច- សិក្សាកំណត់តំបន់រ៉ែមាសនិងត្បូង ដែលមិនមានសក្តានុពលសេដ្ឋកិច្ចសម្រាប់បម្រើឱ្យឧស្សាហកម្មរ៉ែ ដែលស្ថិតក្នុងដីសាធារណៈរបស់រដ្ឋឬដីកម្មសិទ្ធិឯកជន ហើយបង្វែរទិសនិង

ជំរុញឱ្យអ្នកធ្វើអាជីវកម្មរ៉ែដែលគ្មានការអនុញ្ញាតមកធ្វើអាជីវកម្មស្របច្បាប់តាមបែបសិប្បកម្ម ឬអាជីវកម្មរ៉ែខ្នាតតូចវិញ។

ឆ- ជំរុញការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធក្នុងការទប់ស្កាត់អាជីវកម្មធនធានរ៉ែដែលគ្មានការអនុញ្ញាត។

ជ- រៀបចំអភិក្រមតួនាទីរបស់សង្គមស៊ីវិលក្នុងកិច្ចសហការជាមួយនឹងរាជរដ្ឋាភិបាលដើម្បីទប់ស្កាត់អាជីវកម្មធនធានរ៉ែដែលគ្មានការអនុញ្ញាត ដោយផ្តល់លទ្ធភាពឱ្យសង្គមស៊ីវិលអាចផ្តល់ព័ត៌មានជាក់ស្តែងដល់ស្ថាប័នមានសមត្ថកិច្ចនិងផ្តល់យោបល់ក្នុងន័យស្ថាបនា ដោយសហការជាមួយនឹងរាជរដ្ឋាភិបាលក្នុងការធ្វើការអប់រំបណ្តុះបណ្តាល និងជំរុញការធ្វើពិពិធកម្មមុខរបរដល់អ្នកធ្វើអាជីវកម្មធនធានរ៉ែដែលគ្មានការអនុញ្ញាត។

## គោលដៅទី៥- ធនធានរ៉ែនិងការនាំចេញ

### ១- នយោបាយនាំចេញ

ទន្ទឹមនឹងទស្សនៈនៃការប្រមូលយកឱ្យបាននូវតម្លៃសេដ្ឋកិច្ចអតិបរមាពីធនធានរ៉ែ ដោយការបង្កើននូវសកម្មភាពសេដ្ឋកិច្ច ចំណូលពន្ធ និងការផ្តល់នូវការងារដល់ប្រជាពលរដ្ឋ រាជរដ្ឋាភិបាលក៏ពិចារណាក្នុងទស្សនាទានអភិក្រមសនិទាន (Rational Approach) ចំពោះនយោបាយនាំចេញផលិតផលរ៉ែនេះដែរ ដែលតម្រូវឱ្យធ្វើការវិភាគយ៉ាងស៊ីជម្រៅពីការចំណាយ-ផលចំណេញ (Cost-Benefit Analysis) ពីលក្ខណៈបច្ចេកទេសនៃប្រព្រឹត្តិកម្មរ៉ែនិងពីកត្តាសំខាន់ផ្សេងៗទៀត។ ការធានានូវការនាំចេញផលិតផលរ៉ែក្នុងឧត្តមភាពប្រៀបធៀប (Comparative Advantage) គឺជាកត្តាគន្លឹះក្នុងការធ្វើសេចក្តីសម្រេចវិនិយោគ ជាពិសេស លើការវិនិយោគដោយផ្ទាល់ពីបរទេស (Foreign Direct Investment) លើវិស័យរ៉ែនេះ។

រាជរដ្ឋាភិបាលអនុញ្ញាតឱ្យនាំចេញទៅក្រៅប្រទេស តែផលិតផលរ៉ែដែលបានឆ្លងកាត់ការវាយតម្លៃជាវិជ្ជមាននូវឧត្តមភាពប្រៀបធៀបសេដ្ឋកិច្ចនិងផលប្រយោជន៍សង្គមនិងបរិស្ថាន។

ដើម្បីវាយតម្លៃផលប្រយោជន៍សេដ្ឋកិច្ច សង្គម និងបរិស្ថាន រាជរដ្ឋាភិបាលនឹងពិចារណាលើកត្តាដូចខាងក្រោម៖

- ផលប្រយោជន៍សេដ្ឋកិច្ចសង្គមរយៈពេលខ្លីនិងរយៈពេលវែងនៃការនាំចេញផលិតផលរ៉ែមានទំហំធំជាងការជំរុញឱ្យធ្វើប្រព្រឹត្តិកម្មបន្តឬកែច្នៃបន្តនៅក្នុងស្រុក
- ការធ្វើប្រព្រឹត្តិកម្មបន្តឬកែច្នៃបន្តផលិតផលរ៉ែនៅក្នុងស្រុកមានផលប៉ះពាល់អវិជ្ជមានដល់បរិស្ថាននិងសង្គមធ្ងន់ធ្ងរ
- ផលិតផលរ៉ែមានបរិមាណច្រើនលើសពីតម្រូវការផ្គត់ផ្គង់ឧស្សាហកម្មក្នុងស្រុក។

**ផែនការសកម្មភាព** :

ក- រៀបចំលិខិតបទដ្ឋានគតិយុត្តអំពីការគ្រប់គ្រងការនាំចេញផលិតផលរ៉ែដោយពិនិត្យពិចារណាអំពីផលិតផលរ៉ែដែលអាចយកមកធ្វើប្រព្រឹត្តិកម្មបន្តឬកែច្នៃឬធ្វើជាវត្ថុធាតុដើមបម្រើឱ្យឧស្សាហកម្មក្នុងស្រុក ដូចជាផលិតផលរ៉ែដែលបានមកពីរ៉ែឧស្សាហកម្ម រ៉ែលោហៈ ឬរ៉ែអលោហៈផ្សេងៗព្រមទាំងផលិតផលរ៉ែសំណង់។

ខ- រៀបចំបញ្ជីយថាប្រភេទផលិតផលរ៉ែដែលអាចនាំចេញបានដោយផ្អែកទៅលើការវាយតម្លៃឧត្តមភាពប្រៀបធៀបសេដ្ឋកិច្ចនិងផលប្រយោជន៍សង្គមនិងបរិស្ថាន។ បញ្ជីនេះត្រូវធ្វើបច្ចុប្បន្នកម្មយ៉ាងយូរបីឆ្នាំម្តង។

**២- ការនាំចេញផលិតផលរ៉ែក្នុងលទ្ធភាពផ្តល់នូវតម្លៃបន្ថែមខ្ពស់**

ការអនុញ្ញាតឱ្យនាំចេញផលិតផលរ៉ែត្រូវគិតគូរទៅដល់តម្លៃបន្ថែមឱ្យបានច្រើនតាមដែលអាចធ្វើបានដោយយកចិត្តទុកដាក់ខ្ពស់លើការប្រើប្រាស់បច្ចេកវិទ្យាទំនើបនិងការប្រែប្រួលតម្រូវការលើទីផ្សារអន្តរជាតិ ដើម្បីនាំមកនូវឧត្តមភាពអតិបរមា (Maximum Advantage) ពីពាណិជ្ជកម្មបរទេស។

**ផែនការសកម្មភាព** :

ក- លើកទឹកចិត្តក្នុងការសិក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍ (R&D) ដើម្បីធ្វើឱ្យកាន់តែប្រសើរឡើងនូវផលិតភាព។

ខ- លើកទឹកចិត្តក្នុងការកែច្នៃធនធានរ៉ែនិងផលិតផលរ៉ែ មុនធ្វើការនាំចេញ។

គ- ពិនិត្យសិក្សាតម្លៃផលិតផលរ៉ែលើទីផ្សារអន្តរជាតិជាប្រចាំ ដើម្បីបម្រើឱ្យការធ្វើសេចក្តីសម្រេចដ៏ត្រឹមត្រូវក្នុងយុទ្ធសាស្ត្រនាំចេញផលិតផលរ៉ែ។

ឃ- ពិនិត្យសិក្សាអំពីបម្រែបម្រួលតម្រូវការផលិតផលរ៉ែទាំងក្នុងពេលបច្ចុប្បន្នក៏ដូចជាការនិទស្សន៍ពីបម្រែបម្រួលនាពេលអនាគត។

**៣- ការសម្រួលពាណិជ្ជកម្ម**

រាជរដ្ឋាភិបាលយកចិត្តទុកដាក់រៀបចំនីតិវិធីនៃការនាំចេញដោយការសម្រួលពាណិជ្ជកម្មនិងបែបបទនាំចេញ។ ទន្ទឹមនេះរាជរដ្ឋាភិបាលទទួលយកមកពិនិត្យពិចារណានូវសំណូមពរសមហេតុផលរបស់វិនិយោគិនដែលស្របតាមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធដោយឈរលើផលប្រយោជន៍ទាំងសងខាង។

**ផែនការសកម្មភាព៖**

ក- សិក្សាកំណត់នីតិវិធីសម្រួលពាណិជ្ជកម្មនិងបែបបទនាំចេញផលិតផលរ៉ែ។

ខ- រៀបចំប្រកាសអន្តរក្រសួងរវាងក្រសួងរ៉ែនិងថាមពលជាមួយនឹងស្ថាប័នដែលពាក់ព័ន្ធនឹងនីតិវិធីសម្រួលពាណិជ្ជកម្មនិងបែបបទនាំចេញនោះ ក្នុងករណីចាំបាច់។

## ៥- ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃ

ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីធនធានរ៉ែ រាជរដ្ឋាភិបាលប្រគល់ភារកិច្ចជូនក្រសួងទទួលបន្ទុកវិស័យរ៉ែ រៀបចំប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាពនិងបញ្ហាប្រឈមក្នុងការអនុវត្តគោលនយោបាយនេះលើគោលដៅ យុទ្ធសាស្ត្រ និងផែនការសកម្មភាពលម្អិតដែលរួមមាន សូចនាករនៃផែនការសកម្មភាព ឆ្នាំគោលដៅនិងរយៈពេលអនុវត្ត និងធ្វើការសម្រេចចិត្តលើវិធានការបន្ទាន់ចាំបាច់ដើម្បីដោះស្រាយបញ្ហាប្រឈមចំពោះមុខដែលកើតមានឡើងក្នុងពេលអនុវត្ត។

គណៈកម្មាធិការតាមដានត្រួតពិនិត្យនិងវាយតម្លៃវឌ្ឍនភាពក្នុងការអនុវត្តគោលនយោបាយនឹងត្រូវបង្កើតឡើងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

ផែនការសកម្មភាពត្រូវពិនិត្យនិងកែសម្រួលរៀងរាល់បីឆ្នាំម្តង ដោយមានការពិគ្រោះយោបល់ជាមួយនឹងក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ សង្គមស៊ីវិល និងក្រុមហ៊ុនរ៉ែ។

ក្រសួងទទួលបន្ទុកវិស័យរ៉ែត្រូវធ្វើរបាយការណ៍ប្រចាំឆ្នាំជូនរាជរដ្ឋាភិបាល។

## ៦- សេចក្តីសន្និដ្ឋាន

គោលនយោបាយជាតិស្តីពីធនធានរ៉ែជាផែនទីបង្ហាញផ្លូវដើម្បីឱ្យប្រតិបត្តិការធនធានរ៉ែទទួលបាននូវតម្លៃសេដ្ឋកិច្ចអតិបរមានិងកាត់បន្ថយផលប៉ះពាល់ដល់បរិស្ថាននិងសង្គម ព្រោះថារាល់ការអភិវឌ្ឍតែងតែបង្កផលប៉ះពាល់ដល់បរិស្ថាននិងសង្គមទោះតិចឬច្រើន។ យន្តការនៃការពិគ្រោះយោបល់យ៉ាងទូលំទូលាយ ប្រព័ន្ធនៃការត្រួតពិនិត្យ (Monitoring) និងការទទួលបានព័ត៌មានត្រឡប់វិញ (Feedback) យន្តការនៃការវាយតម្លៃផលប៉ះពាល់បរិស្ថាននិងសង្គម ការប្រើប្រាស់អភិក្រមឆ្លើយតបប្រកបដោយការទទួលខុសត្រូវរួមនឹងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលនឹងកាត់បន្ថយបានជាអតិបរមានូវផលអវិជ្ជមានដល់បរិស្ថាននិងសង្គម។

ឆ្លងតាមផែនការសកម្មភាព យុទ្ធសាស្ត្រ និងគោលដៅខាងលើ រាជរដ្ឋាភិបាលនឹងសម្រេចបាននូវគោលបំណងជាចម្បងក្នុងការគ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានរ៉ែប្រកបដោយចីរភាព ផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋនិងសហគមន៍រ៉ែ និងផ្គត់ផ្គង់វត្ថុធាតុដើមដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនិងសំណង់។ លើសពីនេះទៅទៀត ការអភិវឌ្ឍឧស្សាហកម្មធនធានរ៉ែនឹងបង្កើតប្រភពចំណូលថ្មីសម្រាប់ជាតិនិងបង្កើតផលិតផលក្នុងស្រុកថ្មីជំនួសឱ្យការនាំចូល។

ពិតណាស់ថា បច្ចុប្បន្ននេះអាជីវកម្មធនធានរ៉ែមិនទាន់ឈានដល់ដំណាក់កាលឧស្សាហកម្មរ៉ែនៅឡើយ ប៉ុន្តែការត្រៀមរៀបចំជាមុនសម្រាប់ការមកដល់នៃឧស្សាហកម្មនេះ នឹងជួយឱ្យកម្ពុជាកាត់បន្ថយបាននូវបញ្ហាប្រឈមនានា ដែលបណ្តាប្រទេសឧស្សាហកម្មរ៉ែផ្សេងៗទៀតបានឆ្លងកាត់រួច។ មេរៀន បទពិសោធ រួមទាំងឧត្តមានុវត្តន៍ ដែលប្រទេសឧស្សាហកម្មរ៉ែជឿនលឿន ក៏ដូចជាប្រទេសដែលកំពុងតែចាប់ផ្តើមនូវឧស្សាហកម្មរ៉ែនេះនឹងក្លាយជាផែនទីបង្ហាញផ្លូវមួយសម្រាប់កម្ពុជា ក្នុងការធ្វើយ៉ាងណាឱ្យការអភិវឌ្ឍធនធានរ៉ែរបស់យើងមានចីរភាពនិងផ្តល់នូវវឌ្ឍនភាពដល់សេដ្ឋកិច្ច សង្គម និងប្រជាជន។

រាជរដ្ឋាភិបាលប្តេជ្ញាអនុវត្តគោលនយោបាយជាតិស្តីពីធនធានរ៉ែនេះឱ្យសម្រេចបានដោយជោគជ័យ ហើយជឿជាក់ថាការចូលរួមរបស់អ្នកពាក់ព័ន្ធទាំងអស់នឹងជាកម្លាំងចលករដ៏សំខាន់ក្នុងការជួយឱ្យសម្រេចបានយ៉ាងមានប្រសិទ្ធភាពនូវគោលដៅទាំងឡាយដែលបានដាក់ចេញ។

## សន្ទានុក្រម

**ការស្វែងរុករក** សំដៅដល់ការសិក្សាស្រាវជ្រាវក្នុងបំណងរកឱ្យឃើញ ធ្វើតេស្តសន្ទស្សន៍រ៉ែ ដើម្បីកំណត់សក្តានុពល ទំហំ គុណភាព បរិមាណ ព្រមទាំងលទ្ធភាពសេដ្ឋកិច្ច អាជីវកម្មតាមរយៈការធ្វើបុរេសនា ការស្រាវជ្រាវភូគព្ភសាស្ត្រ រូបភូគព្ភសាស្ត្រ និងគីមីភូគព្ភសាស្ត្រ ការជីកកកាយ ការខួង ការដឹកជញ្ជូន និងការធ្វើវិភាគដី ដីល្បាប់ ទឹក ថ្ម និងគំរូរ៉ែផ្សេងៗទៀត។

**ដំណាក់កាលសិក្សាដំបូង** សំដៅដល់ដំណាក់កាលដំបូងនៃការសិក្សាធនធានរ៉ែ ក្នុងគោលបំណងស្វែងយល់អំពីលក្ខណៈភូមិសាស្ត្រនិងភូគព្ភសាស្ត្រទូទៅនៃតំបន់ណាមួយដើម្បីឈានទៅកំណត់អំពីលទ្ធភាពនៃវត្តមានខនិជកម្មរ៉ែ។

**ដំណាក់កាលអាជីវកម្ម** សំដៅដល់ដំណាក់កាលដែលធនធានរ៉ែត្រូវបានជីកយក ធ្វើប្រព្រឹត្តិកម្ម ដឹកជញ្ជូន និងលក់ដូរឬនាំចេញក្នុងគោលបំណងពាណិជ្ជកម្ម។

**ដំណើរការប្រព្រឹត្តិកម្មរ៉ែ** សំដៅដល់ដំណើរការប្រតិបត្តិការធនធានរ៉ែ ចាប់ផ្តើមពីការកិនបំបែករ៉ែ រហូតដល់ការចម្រាញ់និងបន្សុទ្ធរ៉ែ។

**តួនាទីដែលមិនមែនជាបញ្ញត្តិកម្ម** សំដៅដល់តួនាទីណែនាំមួយចំនួនដែលគ្មានលក្ខណៈជាបទបញ្ញាគតិយុត្ត។

**ទិន្នន័យភូគព្ភវិទ្យាសាស្ត្រ** សំដៅដល់ទិន្នន័យដែលទទួលបានពីការសិក្សាភូគព្ភសាស្ត្រនានា។

**ទិន្នន័យភូគព្ភសាស្ត្រ** សំដៅដល់រាល់ទិន្នន័យដែលពាក់ព័ន្ធទៅនឹងផែនដី។

**រ៉ែវិទ្យុសកម្ម** សំដៅដល់ធនធានរ៉ែដែលមានផ្ទុកនូវសារធាតុវិទ្យុសកម្ម អ៊ុយរ៉ាញ៉ូម (U) ឬតូរីយ៉ូម(Th)។

**នីតិសម្បទាអណ្តូងរ៉ែ** សំដៅដល់ការកែប្រែអណ្តូងរ៉ែដែលត្រូវបានបិទឱ្យមានសភាពល្អប្រសើរឡើងវិញសម្រាប់ការរស់នៅនិងបរិស្ថានធម្មតា។

**បុរេសនា** សំដៅដល់ការស្វែងរុករកធនធានរ៉ែជំហានដំបូងនៅស្រទាប់ដីលើ ដោយប្រើប្រាស់ឧបករណ៍សាមញ្ញ ហើយមានការប៉ះពាល់បន្តិចបន្តួចដល់ផ្ទៃដី ដើម្បីកំណត់វត្តមានធនធានរ៉ែដែលមានតម្លៃពាណិជ្ជកម្ម និងអាចជាទិសដៅសម្រាប់ការស្នើសុំអាជ្ញាបណ្ណស្វែងរុករកនិងអាជីវកម្មធនធានរ៉ែ។

**ប្រតិបត្តិការធនធានរ៉ែ** សំដៅដល់ការធ្វើសកម្មភាពបុរេសនា ស្វែងរុករក និងអាជីវកម្មធនធានរ៉ែ។

**ផលិតផលរ៉ែ** សំដៅដល់ផលិតផលគ្រប់ប្រភេទ ដែលជីកយកចេញពីអណ្តូងរ៉ែ ឬដែលបានឆ្លងកាត់ប្រព្រឹត្តិកម្មរាប់ចាប់តាំងពីបំណែករ៉ែរហូតដល់លោហធាតុ។

**ផែនការការទទួលខុសត្រូវសង្គមរួម** សំដៅដល់ផែនការដែលរួមចំណែកដល់កិច្ចការសង្គម តាមរយៈការផ្តល់ចំណែកនៃផលចំណេញពីធុរកិច្ចរ៉ែ។

**ផែនទីតិចតូនិច** សំដៅដល់ផែនទីដែលបង្ហាញពីរចនាសម្ព័ន្ធនៃសំបកផែនដី (earth crust) និងឆ្លុះបញ្ចាំងពីដំណាក់កាលសំខាន់ៗនៃការវិវត្តរបស់សំបកផែនដី។

**ផែនទីភូគព្ភសាស្ត្រ** សំដៅដល់ផែនទីដែលបង្ហាញនូវប្រភេទ អាយុនិងទីតាំងសិលា រួមទាំងលក្ខណៈទ្រង់ទ្រាយនៃស្រទាប់សិលា។

**ភូគព្ភសាស្ត្របរិស្ថាន** សំដៅដល់វិទ្យាសាស្ត្រដែលប្រើប្រាស់គោលការណ៍ឬព័ត៌មានភូគព្ភសាស្ត្រ ដើម្បីសិក្សាអំពីបម្រែបម្រួលបរិស្ថានផែនដី។

**សំណាកគំរូរ៉ែ** សំដៅដល់សំណាករ៉ែ ដែលប្រើប្រាស់សម្រាប់ការធ្វើពិសោធន៍វិភាគបរិមាណនិងគុណភាពរ៉ែ ឬរក្សាទុកជាគំរូ។

**សំណាកភូគព្ភសាស្ត្រ** សំដៅដល់សំណាកគ្រប់ប្រភេទដែលជាផលិតផលនៃផែនដី រួមមានសំណាកសិលា សំណាករ៉ែរឹង រាវ សំណាកហ្វូស៊ីល។ល។

**អតិក្រមសន្និធាន** សំដៅដល់វិធីសមហេតុសមផលដោយផ្អែកលើមូលហេតុឬតក្កភាព។

**អាជីវកម្មធនធានរ៉ែ** សំដៅដល់ប្រតិបត្តិការជីកយកធនធានរ៉ែដែលក្នុងនោះធនធានរ៉ែត្រូវបានយកចេញពីជម្រករ៉ែ ធ្វើប្រព្រឹត្តិកម្ម ដឹកជញ្ជូន លក់ដូរ ឬការនាំចេញក្នុងគោលបំណងពាណិជ្ជកម្ម។